# រឿងទុំទាវ

ព្រះបទុមត្ថេរ សោម

ភ្នំពេញ

ការផ្សាយរបស់ពុទ្ធសាសនបណ្ឌិត្យ

ព.ស.២៥១៤

## អារម្ភកថា

### របស់ពុទ្ធសាសនបណ្ឌិត្យ

រឿងទុំទាវនេះ មិនមែនជារឿងព្រេង និងមិនមែនជារឿងជាតកទេ គឺជារឿងមួយកើតឡើងពីការដកស្រង់នៃបញ្ហាជីវិតខ្មែរយើង ដែលធ្លាប់មានពិតប្រាកដក្នុងសម័យទីក្រុងលង្វែក ដូចមានសេចក្តីពិស្តារក្នុងផ្ទៃរឿងនេះ ជាភ័ស្តុតាងស្រាប់ ។

វិជ្ជាឋានពុទ្ធសាសនបណ្ឌិត្យ បានស្រាវជ្រាវរកឃើញនូវរឿង ទុំទាវនេះ មានពីរបែបគឺៈ

១- ច្បាប់របស់លោកគ្រូព្រះបទុមត្ថេរព្រះនាម សោម ចៅអធិការវត្តកំព្រៅ ឃុំកំព្រៅ ស្រុកស៊ីធរកណ្តាល ខេត្តព្រៃវែង តែងក្នុង ព.ស ២៤៥៨ គ.ស ១៩១៥ រជ្ជកាលព្រះបាទស៊ីសុវត្ថិ រៀបរៀងជាកាព្យពាក្យ ៧ ពីដើមដល់ចប់ ។

២- ច្បាប់របស់លោកឧកញ៉ាវិបុលរាជសេនា **នូ កន** តែងជាកាព្យពាក្យ ៨ ក្នុងព.ស ២៤៨៥ គ.ស១៩៤២ រជ្ជកាលព្រះបាទនរោត្តមសីហនុ តែច្បាប់របស់លោក **នូ កន** ប្រែឈ្មោះថា «**រឿង ទាវឯក** »ទៅវិញ ព្រមទាំងបញ្ចូលគំនិតផ្ទាល់ខ្លួនជាច្រើនផង ។

វិជ្ជាឋានពុទ្ធសាសនបណ្ឌិត្យ បានចាត់ការចម្លងយករឿង **ទុំទាវ** ចេញពីច្បាប់សាស្ត្រាស្លឹករឹតរបស់លោកគ្រូព្រះបទុមត្ថេរ ព្រះនាម **សោម** ដែលមាននៅក្នុងបណ្ណាល័យរបស់វិជ្ជាឋាននេះមកពិនិត្យផ្ទៀងផ្ទាត់ ហើយចាត់ការបោះពុម្ពឡើង ដើម្បីរក្សាស្នាដៃកវីនិពន្ធខ្មែរសម័យបុរាណទុកជាកេរ្តិ៍តទៅកុំអោយបាត់បង់ និងដើម្បីអោយអ្នកអាន :

ក) - បានស្គាល់ច្បាស់ថា ជាតិខ្មែរយើងមានកេរមត៌កអក្សរសាស្ត្រច្រើនបែប ពិសេសជាបែបប្រលោមលោក ប៉ុន្តែសរសេរជាពាក្យកាព្យ ។

ខ) - បានស្គាល់ព្រឹត្តិការណ៍អក្សរសាស្ត្រខ្មែរ សម័យបុរាណ ។

គ) - បានចេះចាំរឿងនិទាន និងពាក្យខ្មែរបុរាណច្រើន បែកប្រាជ្ញាអាចធ្វើការចរចានិងការនិពន្ធរបស់ខ្លួនអោយមានសម្រស់ ។

ឃ) - បានប្រៀបធៀបវោហារពាក្យពេចន៍សម័យចាស់ និងសម័យថ្មី ហើយធ្វើសេចក្តីនិពន្ធរបស់ខ្លួនអោយមានលម្អ អោយត្រូវគ្រប់សម័យ ។

ការចម្លង និងការពិនិត្យផ្ទៀងផ្ទាត់នេះ បានទុករឿងនិងពាក្យកាព្យ ក្នុងផ្ទៃរឿងអោយនៅតាមច្បាប់ដើម ឥតកែប្រែ. គ្រាន់តែសម្រួលពាក្យខ្លះ ដែលយល់ច្បាស់ថា កត់ដោយការចម្លងត១គ្នាជាច្រើនតំណមកហើយ អោយត្រឹមត្រូវតាមច្បាប់ដើមវិញ នឹងគ្រាន់តែប្រើអក្សរតាមវចនានុក្រមខ្មែរសម័យបច្ចុប្បន្នប៉ុណ្ណោះ ។

វិជ្ជាឋានពុទ្ធសាសនបណ្ឌិត្យ សង្ឃឹមថា សៀវភៅរឿង **ទុំទាវ** នេះ នឹងបានជាកម្លាំងមួយអាចជួយពង្រីកអក្សរសាស្ត្រជាតិ អោយមានវឌ្ឍនាការជាភិយ្យោភាពតទៅ ។

**លាង ហាប់អាន**

នាយកវិជ្ជាឋានពុទ្ធសាសនបណ្ឌិត្យ

# អារម្ភបទ
## របស់រឿង ទុំទាវ

(បទពាក្យ ៧)

១. នេះនឹងថ្លាថ្លែងតែងចរចា    ល្បើកល្បងល្បែងល្បាយកាយកាព្យា
តាំងតែដំណាលកាលមុនជា    និទានយូរយារឃ្លាឃ្លាតឆ្ងាយ ។
មិនទៀងល្បៀងល្អក់តក់ឃ្លាឃ្លាត    សង្ខាតផ្ទៀងផ្ទាត់បទបរិយាយ
យើងកែជាថ្មីផែនដីអាយ    ស្រង់ស្រាយតទុកទៅមុខទៀត ។
ខិតខំសន្សំកែតិតជូស    ក្រែងហួសកិរៈស័្មគ្រប្រឹងឆ្លៀត
កុំមានវោហារថាចោលម្សៀត    បែរបៀតត្រូវកាលដំណាលកើ្ត ។
នាមានាមំតាំងជាថ្មី    ក្នុងដែនលោកកិយគន់គិតត្បេរ
គិតគ្នាន់ក្នុងអង្គផ្ទង់កាយេ    គិតយកមកផ្ទេរផ្ទៀងទៀងទុក ។
៥. អោយអស់មហាជនជាតិប្រុសស្រី    ក្នុងដែនលោកកិយដឹងទៅមុខ
គ្រាន់ជាលំហែកែអផ្សុក    វិតក្កកាលណាត្លាំរីករាយ ។
យើងនឹងថ្លែងនាមតាមបញ្ញា    ដើមថាតាមឈ្មោះចំពោះងាយ
តួ **ស** រាប់រៀបធៀបនិយាយ    ទើបទាយប្រកបរាប់រៀងទៅ ។
ទាញយា **ស** សព្ទប្រកប **ម**    ប៉ាំងឈើលើ **ស** ទើបបានត្រូវ
ឈ្មោះដើមដូចនឹងពីម៉ែឪ    ឥឡូវនាមបែកចែកដោយគុណ ។
ចូលមកសំណាក់សំណាងមាន    ព្រះគុណអោយទានទុកជាទុន
ជាទីគ្រាន់បានប្រាណរស់ជន្ម    ដោយបុណ្យរ័តន៍ត្រៃសព្វថ្ងៃពីង ។
ចូលមកសំណាក់បួសគង់នៅ    ទីវត្តកំព្រៅឈ្មោះសភ្លឹង
កាត់សង្សារវដ្តវាសវាំងនឹង    ឡើយព្រួយព្រោះប្រឹងប្រាថ្នាផល ។
១០. នាមនោះចំពោះឧបជ្ឈាចារ្យ    ដូចផ្កាក្រអូបផុំច្រាសខ្យល់
ព្រះបទុមត្ថេរបែរបានផល    កំណត់កុសលសាងសីលទាន ។
ស្តេចសង្ឃមេត្តាត្រាប្រណី    សម្រេចលើដីលោកិយគ្មាន



នាយកខាងសង្ឃក្នុងក្រុងមាន    សង្ឃផងស្រែកឃ្លានមានបញ្ញា ។
ចូលទៅដែនក្រុងផ្ទង់ឈ្មោះស្ម័គ្រ    ប្រាថ្នាពឹងពាក់តាមប្រាថ្នា
រៀនសូត្របាលីអត្ថបញ្ហា    ចិន្តាផ្គាប់ផ្គុនបុណ្យបារមី ។
ទ្រង់ប្រោសប្រទានអោយមានឈ្មោះ    ចំពោះជាបានដូចសេចក្តី
ប្រាថ្នាការងារ ឬ គិតអ្វី    ប្រណីប្រោសប្រាណប្រទានមក ។
តាំងព្រះឧបជ្ឈាយ៍ងារព្រះស-    ង្ឃៈវក្សគង់នឹងពឹងពន្លក
ពន្លឺលោកិយនិស្ស័យជ្រក    ចូលមកកាលណាបោះត្រាអោយ ។
១៥. កាន់ដើររកស៊ីទៅឆ្ងាយជិត    មិនមានភ័យភិតនឹងចីបោយ
ប្រកាន់ផែកឆែរទីដីដោយ    គ្មានកាតថ្នោះថ្នោយអោយលើកដី ។
យើងលើកកាព្យកាលពុទ្ធសាសនា    ពីរពាន់វស្សាផ្សំសិរី
បួនរយហាសិបប្លាយប្រាំបី    ថ្ងៃចន្ទដប់បួនរាប់នូវខែ ។
កន្លងបានបួនជូនភទ្របទ    មួយកើតកំណត់វស្សន្តេ
ឆ្នាំថោះសប្តស័កមិនហួរហែ    សល់ទៅទៀតឯមុខមិនថ្លែង ។
ទុកអោយអ្នកក្រោយទោះលោកណា    មែនមានប្រាជ្ញាចេះតុបតែង
គិតចុះសល់ទុកមិនសម្តែង    ចេះអ្វីតែងឯក្រែងគេថា ។
ចារចែងសម្តែងរិះរៀបរាប់    ទុកជាសណ្តាប់ក្នុងសាសនា
សូមលើកករផ្ទង់នមស្ការ    ដល់ព្រះសម្មាសម្ពុទ្ធស្ស ។
២០. នូវគុណព្រះធម៌ធំទូលាយ    ប្រាំបីម៉ឺនប្លាយបួនពាន់ខ្ពស់
ជ្រៅច្រើនក្រវើនត្រាច់ប្រោសប្រោះ    សត្វមនុស្សដាក់ដល់ថ្កល់និព្វាន ។
នូវគុណព្រះសង្ឃអង្គសាវ័ក    លោកភ័យផ្អើលភ្ញាក់មិនស្រែកឃ្លាន[1]
ចាកសង្សារវដ្តប្រាកដមាន    ទុកដាក់ផ្ញើទានមានសង្ឃស- ។
ម្មតិឋិតធូនថៃក្នុងសាសនា    ប្រៀបដូចភេត្រារិះរៀបចំ
រៀនគន្ថធុរៈជាក់ឧត្តម    ប្រឹងខំក្រែងខុសថ្លោះវិន័យ ។

១. គួរថា លោកមិនផ្អើលភ្ញាក់ភ័យស្រែកឃ្លាន ។

សូមគុណព្រះឧបជ្ឈាយាចារ្យ មាតាបិតានូវព្រះពៃ-
ស្រពស្រង់រូចរស់រូបទីទៃ ឥតអ្វីប្រៀបផ្ទឹមត្រឹមស្មើបាន ។
នូវគុណព្រះកម្មវាចា អនុស្សាវនាបង្កើតប្រាណ
គុណព្រះវិន័យព្រះកម្មដ្ឋាន ផាត់ច្រានផុតទុក្ខសុខសួគ៌ា ។

២៥. គុណព្រះអគ្គីវារីឫទ្ធ ព្រះអាទិត្យធរណីព្រះចន្ទ្រា
ព្រះពាយតារាទេពទេវា ឋិតគុកគុហាសោឡសស្ថាន ។
ព្រះកាលព្រះយមរាជា ចតុលោកបាលឋិតសម្រាន្ត
គង់ចាតុម្មហារាជស្មោះស្មាន កំសាន្តគង់នៅតាវត្តិង្សា ។
ព្រះឥន្ទ្រាទ្រង់គង់សោយរាជ្យ រិទ្ធីអំណាចមានចេស្តា
ទាំងសោឡសសួគ៌ទេវតា ព្រះវិស្សកម្មាប្រតិស្ថាន ។
សូមសុំតេជះលោកទាំងគ្រប់ ជាម្លប់គ្រាន់ជ្រកកោនសម្រាន្ត
សម្រេចជៀសទុក្ខសុខក្នុងប្រាណ អោយបានដូចចិត្តគិតប្រាថ្នា ។
ទោះទាំងរោគាព្យាធិអ្វី កុំបីអោយមានក្នុងកាយា
សូមជ្រះស្រឡះអង្គរូបា ភ្លឺថ្លាត្រចង់ដូចវង់ខែ ។





# រឿង ទុំទាវ

( បទពាក្យ ៧ )

៣០. ថ្លាថ្លែងសម្ដែងដើមឈ្មោះទុំ    នៅខេត្តបាភ្នំដែនដីស្រែ
កើតកបទំនៀមមានឪម៉ែ    ប៉ុន្តែហេតុត្បិតឥតសម្ដែង ។
កើតឡើងលុះធំល្មមប្រមាណ    ឆ្នាំច្រើនសោតបានម្ដាយតុបតែង
យកទៅអោយរៀនចោលគ្រឿងល្បែង    ស្វះស្វែងនៅវត្តវិហារធំ ។
លោកគ្រូទទួលស្រួលព្រះទ័យ    ប្រឹតប្រៀនទុំឱ្យខាងអាគម
អាចគាប់ដោយប្រាជ្ញប្រឹងជព្រុំ    ខិតខំចង់បួសផ្នួសសាមណេរ ។
សំណាក់ឋិតថេរចំណេរលង់    មាននេនមួយអង្គគ្រាន់បើដែរ
នាមឈ្មោះនេនពេជ្រលេចក្រសែ    នេនទាំងពីរកែតែតោកលក់ ។
៣៥. ទុំមានវោហារប្រាជ្ញាផ្សេង    មានទាំងសម្លេងរូបខ្ចីល្អក់
ល្អទ្រង់អង្គកាយសាយទឹកមុខ    រូបទុកនេនពេជ្រស្រេចជាប្អូន ។
នេនពេជ្រចេះស្រេចខាងផ្លុំប៉ី    ឈ្លាសវៃប្រសប់ភ្លេងមាំមួន
អ្នកនេនពីរពិតគិតគុំកួន    ចំណេះក្នុងខ្លួនប្រហែលគ្នា ។
ធ្វើតោកធ្វើទុកលក់ដាច់ខ្លះ    នៅផ្ទះទៀបវត្តជាមីងមា
លុះដល់រដូវត្រូវរងា    ព្រឺប្រុងអង្គាជាទុក្ខព្រួយ ។
អកុសលដល់គ្រប់សង្កត់កាយ    ជួបនេនពេជ្រវាយដូចខ្លួនមួយ
ថានេនពេជ្រអើយចូរគាត់ជួយ    យើងលក់តោកមួយៗយូរហើយ ។
វាគ្មានចំណេញជំនួញទាល់    កុំឆ្ងល់ដូចពាក្យបុរាណឆ្លើយ
ថានៅវៀងអាយជិតបង្កើយ    លំហែលំហើយតែបូនស្រី ។
បុរាណលោកថាមិនខុសសោះ    ខ្លួនយើងកម្លោះក្នុងលោកិយ
បួសស៊ីបាយបាត្រមិនចេះអ្វី    នៅថ្វីចោលម្សៀតឆ្មៀតដើរឆ្ងាយ ។
៤០. គិតស្រេចព្រមព្រៀងមៀងមើលគ្រប់    ខំទប់មិនឈ្នះរៀបខ្វល់ខ្វាយ
ទៀនធូបបានស្រាប់ប្រញាប់កាយ    ឡើងដាក់អង្គថ្វាយបង្គំគាល់ ។



លោកគ្រូពុំយូរមានពុទ្ធដីកា    ថានេនទៅណាដូចពីកាល់
នេនទទួលពុទ្ធដីកាថាទាំងទាល់    ក្រាបទូលកុំឆ្ងល់សូមមេត្តា ។
ព្រោះយើងទាំងសងប៉ីងបង្គំ    លាព្រះគុណធំខ្ញុំករុណា
ទាំងពីរនាក់នឹងចរយាត្រា    ប្រោសប្រាណមានការទៅស្រុកឆ្ងាយ ។
នៅវត្តប្រាកដជាអផ្សុក    ជាទុក្ខគ្មានល្ហែក្នុងអង្គកាយ
ខ្ជិលណាស់ព្រះគុណមិនសប្បាយ    ក្រហល់ក្រហាយខ្វល់ចង់ដើរ ។
ដោយសារគ្រូវខ្យល់ដល់រដូវ    លាព្រះគុណទៅក្រែងប្រសើរ
ប្រសិនដឹកតោកយកទៅផ្ញើ    គ្រាន់បើនៅអាយចាយមិនដាច់ ។
៤៥. លោកគ្រូពុំយូរមានពុទ្ធដីកា    ថាអើតាមអាប្រាជ្ញាគ្រាច់
ថាលាអញទៅលក់ដូរស្រេច    ចាំបាច់សារស័ព្ទប្រាប់អញថ្វី ។
ទៅចុះគាប់ខុសប្រយ័ត្នណា    កុំឱ្យអីអាឃើញរូបស្រី
បត់បួចឡកលេងមិនគប្បី    ជំនៀលអប្រិយដល់មកគ្រូ ។
កើរ្តិ៍ខ្ញាស់និន្ទានាលោកិយ    ខុសពីវិន័យព្រះសព្វញ្ញូ
បើទៅលក់អស់កុំនៅយូរ    គិតគូរថ្លៃថោកមកវិញឆាប់ ។
នេនទាំងពីរកាយថ្វាយបង្គំ    លាលោកគ្រូធំចុះប្រញាប់
ប្រញាយប្រញឹកនឹកឃើញស្រាប់    យកតោករៀបផ្គាប់ផ្គុំបម្រុង ។
ផុកក្នុងរទេះរិះរកបាយ    បានខ្ចប់ខ្វល់ខ្វាយរកការុង
បង្ការប្រេកស្រូវក្រែងផ្លូវផុង    ត្បិតក្នុងរដូវគ្រូវភ្លៀងផ្គរ ។
៥០. នេនរៀបបម្រុងការុងបាយ    បង្កាទៅឆ្ងាយផ្លូវគ្រាច់ចរ
ប្រឹងអូសរទេះមកបញ្ឈរ    ដឹកគោនឹកបរចរចេញទៅ ។
ពារពេលប្រហែលម៉ោងប្រាំបី    សូរ្យសែងរង្សីភ្លឺសន្ធៅ
សន្ទោពីទិសបូព៌ាចោលឆ្នៅ    បរដល់វាលនៅក្នុងខេត្តខណ្ឌ ។
មើលមានទឹកស្មៅខាងផ្លូវស្រាប់    ប្រញាប់ដោះគោចងនេនឆាន់
គោស៊ីស្មៅស្រេចដឹករន្ទាន់    ប្រកាន់ចូលនឹមទឹមបរទៅ ។

ដល់ស្រុកភូមិស្ថានបានលក់គោក    បាសកទិញយកខ្លះសល់នៅ
សល់ខានប៉ុន្មានលក់តាមផ្លូវ    ខំបរដល់ទៅខេត្តត្បូងឃ្មុំ ។
៥៥. ប្រទល់ដែនដល់ខេត្តទទឹង    ថ្ងៃតែងឈប់នឹងត្បិតជនជុំ
ចង់ទិញគោកនេនខ្លះគន់គុំ    សម្លឹងនេនទុំសមរូបឆោម ។
ខ្លះថាអើម្លេះប្រសិនណា    បានអញប្រវាឱបប្រលោម
ប្រឡែងតាមចិត្តគិតចង់ចោម    មៀងមើលព្រឹព្រមប្រឈមឈប់ ។
បៀតបៀនស្នេហ៍ស្និទ្ធជិតអណ្ដូង    ជ្រួលច្រួងស្រើបស្រួលទីទួលម្លប់
ឈ្មោះពោធិជើងខាលត្រកាលគ្រប់    មើលសព្វស្រីប្រុសស្រុះស្រើបស្រាល ។
នេនដាក់ស្នាក់ស្និទ្ធជិតភូមិស្ថាន    ប្រមាណបាសកជួយឈើផ្អាល
លក់ដាច់ដោយយល់ឃើញត្រអាល    បណ្ដាលបណ្ដោយអោយយូរនៅ ។
ឈប់រង់អង់ខានបានច្រើនថ្ងៃ    អាល័យអ្នកនេនមិនអោយទៅ
ចាកទីដែននោះព្រោះយល់ត្រូវ    រដូវដល់ដែលប្រហែលថា ។
៦០. ប្រមាណដោយគិតគំនិតអ្នក    ដែលអោយនេនស្នាក់ប៉ងប្រាថ្នា
ប្រយោជន៍អោយនេនមើលសាស្ត្រា    នេនមានប្រាជ្ញាចេះលេបខាយ ។
សម្លេងផ្អែមល្ហែមស្រួយពីរោះ    ស្ដាប់ទាំងកម្លោះចាស់មេម៉ាយ
ក្រមុំត្បូងឃ្មុំរត់ប្រញាយ    ប្រញាប់ចង់ស្ដាប់ស័ព្ទភាសា ។
កាលនោះនាងនោជាភីលៀង    នាងទាវបានឈៀងចរយាត្រា
កាន់ក្អមថ្មីតថ្មមទឹកប្រាថ្នា    ចូលទៅស្ដាប់ការណ៍ដឹងសេចក្ដី ។
ឈរទ្រឹងរឹងខ្លួនពួនចាំស្ដាប់    ពីរោះហាក់ផ្ដាប់មុខដល់ដី
ស្រងាកស្រងោចស្រងល់ស្រី    នោទឹកបេតីមិនស្ដីសោះ ។
ចាំទៅដល់ផ្ទះប្រាប់ទាវគ្រប់    ទាវនៅក្នុងម្លប់សមស្រណោះ
នាងជាម្ដាយទាវមានរបស់    កូនស្រស់រូបស្រេចដាច់ស្រីផង ។
៦៥. នាទឹកក្នុងចិត្តគិតស្រេចស្រាប់    ដងទឹកទូលឆាប់ដើរផ្សៀងផ្អង
ដល់ផ្ទះនោឡើងទៅជាម្ដង    សាសង៉ាយរ៉ាប់ប្រាប់ទៅថា ។



ទាវអើយទាវស្រីសេចក្ដីនេះ    លោកនេននោះចេះមើលសាស្ត្រា
សម្លេងស្រួយស្រាប់ស្ដាប់ភាសា    ដូចសត្វសារិកាពិសាចេក[១] ។
ទាវទៅនៅយូរគួរពិភាល់    មិនសល់គេប្រាប់ជាក់ហើយត្រេក
ត្រង់នោះកុំឆ្ងល់បានដឹងពេក    តម្រេកប្រឹងស្ដាប់ហ៊ានប្រាប់ម្ដាយ ។
ចេញមកក្រៅក្រាបទៀបមាតា    ទាវថាម៉ែអើយអើម៉ែអាយ
អាណិតកូនម្ដងទើបកូនរាយ    បាសកយើងអាយឆ្ងាយវត្តឋាន ។
មិនដែលស្គាល់សោះកម្លោះលោក    មិនដឹងថាមកពីថ្កាន
ឮនោគេថាមកពីរអង្គប្រាណ    សម្រាន្តកាយយក់លក់គោកលេង ។
ថាមកពីឆ្ងាយដល់អាយស្នាក់    ផ្ទះគេមួយជាក់ជានេនក្មេង
ពីរោះមែនដឹងផ្សឹងតាមឈ្វេង    នោថាសម្លេងមានគ្រាន់បើ ។
៧០. នាងជាម្ដាយទាវផ្ទៀងស្ដែងស្ដាប់    ឮទាវកូនប្រាប់ឆ្លើយថាអើ
លូកដៃយកស្បៃដណ្ដប់ដើរ    ញាំងញើផ្ទៀងឈ្មងទំនងចាស់ ។
បានដល់យល់មនុស្សស្រុះជៀវឆោ    ម្ដាយទាវថាឱមែនជាក់ច្បាស់
ឡើងទៅឃើញនេនតូចល្អណាស់    ផ្គុំហត្ថសំពះក្រាបបង្គំ ។
ហើយទូលសួរថាករុណាម្ចាស់    និមន្តទៅផ្ទះសត្វជាខ្ញុំ
ឆាន់ស្លាបានម្ដងហើយយើងសុំ    និមន្តលោកកុំខានណាំម្ចាស់ ។
នេនទុំបានស្ដាប់ស័ព្ទញោមមន្ត    ភ្នែកតែងតយគន់មើលអោយច្បាស់
ឆ្លើយថាបើមន្តញោមរហ័ស    ទៅផ្ទះរៀបរូចអាចក្ដីទៅ ។
ម្ដាយទាវវិលដល់ផ្ទះម្ទីម្នា    លាតលាកន្ទេលក្រាលដោយនូវ
យកកែបកល់កើយខ្នើយពូថៅ    សខ្មៅគ្រិបប៉ាក់ដាក់ដង្ហែ ។
៧៥. នេនពេជ្រនេនទុំជំនុំព្រម    នេនពេជ្រថាល្មមឆាន់ទៅដែរ
ទុំថាចុះគោនៅក្នុងស្រែ    ដាច់ខ្សែស៊ីស្រូវត្រូវសងគេ ។
នេនពេជ្រគេចថាអើទៅចុះ    បើខុសឆាន់រូចខ្លួនទទេ

១. បោះលើកមុនថា «សត្វសារិកា ឬ ល្វាចេក» តែនេះកែតំរូវតាមសាស្ត្រាដើមវិញ ។

ក្រែងវិលទៅវត្តលោកគ្រូជេ
ថាឯងវេះវេរដើរចង់ស្រី ។
កាត់ដើរគ្រប់ខេត្តហេតុទាងម្លេះ
អាងមានតម្រិះក្នុងលោកិយ
ហៅឆាន់រំលឹកមិនគប្បី
ទំនៀមចាស់ស្ដីមិនចេះខុស ។
ថាដើរមានប្អូនខ្លួនជាសង្ឃ
ទើបបានត្រូវត្រង់ឥតមានមោះ
បើដើរទៅក្ដីបាសកសោះ
កេរកោះថ្លោះធ្លោយអោយមានប្រាំ ។
នេះទៅម្នាក់ឯងក្រែងគេថា
បាសកសិកាគេមកផ្ដាំ
អោយមន្តទៅលេងឆាន់ស្លាថ្នាំ
មន្តចុះឆាន់ចាំគោម្នាក់ឯង ។
៨០. នេនទុំងឿងងំជញ្ជាំគិត
ព្រួយចិត្តត្បិតពេជ្រលេចសម្ដែង
យកសព្ទទំនៀមមកថ្លាថ្លែង
រួចទុំតុបតែងស្បង់សង្ឃាដី ។
សឹងព្រែសូត្រសុទ្ធសាច់ល្អស្អាត
លាំងកែម៉ូតម៉ាតពណ៌លឿងខ្ចី
សម្បុរស្រៀបស្រស់ឆ្អិះរស្មី
នៅថ្មីភ្លឺទៃងកន្សែងស ។
ស្លៀកពាក់គ្រលុំធុំរមៀត
យកផ្លិតសឹកសៀតរូបឆោមល្អ
យាមឈ្មេងទំនងលើកបង់ក
ស្រេចចរចាកទីលិលាទៅ ។
ដល់ផ្ទះម្ដាយទាវចុះមកឆាប់
ដល់ដីអោនក្រាបប្រណមនៅ
ថាទានលោកម្ចាស់និមន្តត្រូវ
ឥឡូវឈប់រង់ស្រង់ទឹកអាង ។
ទឹកអប់ត្រឡប់ធុំគន្ធរស់
សាប៊ូជូតដុសជ្រះសន្លាង
ក្រអូបសាប៊ូក្លិនដោយយ៉ាង
ដោយយល់សំណោងសាមណេរនេន ។
៨៥. ស្រង់ស្រេចផ្លាស់ស្បង់អង្សកពាក់
ឡើងផ្ទះដល់ដាក់អង្គពន់ពេក
លើកបាទបត់បែបកែបប្រគេន
ប្រគល់លោកនេនប្រគេនស្លា ។
ប្រាកដចេះបទយ៉ាងម្ដេចខ្លះ
កុំអន់អៀនខ្មាសសូមមេត្តា
និមន្តសូត្របួមើលសាស្ត្រា
យើងខ្ញុំប្រាថ្នាចង់ស្ដាប់ម្ដង ។
អោយអស់ចំណេះចេះយ៉ាងណា
តាមលោកមេត្តាស្រាយចំណេង
ចំណាំម្ដេចខ្លះខ្ញុំប៉ុនប៉ង
សន្តានមកផងស្ដាប់រាល់គ្នា ។
រួចនេនស្ដាប់ជាក់ភ្ញាក់ព្រើតប្រឹង
ភ្នែកគន់សំលឹងទៅមាត់ទ្វារ





យល់ទាវឈរស្ងួបដើររេរា ស្ទុះស្ទាចូលក្នុងស្នួងចេញក្រៅ ។
៩០. អើតអើមដកកច្រហមាត់ ចង់ចេញប្រាកដគ្មានគេហៅ
ស្អុតស្អុងម្នាក់ឯងដោយក្មេងសាវ ស្ទុះចូលយកអាវពាក់ពានា ។
នេនយល់ដូច្នោះក្នុងពោះព្រួច កាន់កូចកើតទុកចុកឱរា
ឱរូបហ្នឹងហើយទាវពុំងារ មិនងាកបំពារបំពេរន ។
តាំងថានមោតស្សបីបទ ពិរោះប្រាកដខ្លះក្រាបឱន
ស្នូត្រក័ណ្ឌមទ្រីកាលជ្រកកោន លំអោនលាព្រះលះចូលព្រៃ ។
ត្រាច់កាត់ក្នុងដងដែនបព្វតា រកបេះផលាពនាល័យ
មានរុក្ខទេវាផងដទៃ បំភ័យស្លុតស្លន់ភ័ន្តភាំងភិត ។
ដល់ដូលដាក់អង្គទ្រង់វិយោគ ទូញយំឱនឈ្ងោកគួរអាណិត
អនាថត្រដាក់ហើយល្វាចឥត លោកណាជួយគិតជីវិតខ្ញុំ ។
ប្រាសព្រះព្រោះលះមកឆ្ងាយហើយ អម្ចាស់ថ្លៃអើយម្ល៉េះក្រាលក្រំ
ព្រួយប្រឹងគិតកូនខានចង្រ្កម កូនយំទាររកយកអ្វីអោយ ។
៩៥. ស្រែកឃ្លានគ្មានសល់ផលផ្លែឈើ ម្ល៉េះហើយទ្រង់ដើរក៏ដង្ហោយ
ហៅខ្ញុំពីព្រឹកនឹកខានសោយ សមដោយតាមកូនសូន្យស្ងប់ស្ងាត់ ។
នេនស្នូត្រច្រូតកាត់កែទំនង រម្លងយកខាងរឿងបរមត្ថ
ឈប់ឆាន់ស្លាម្លូយូរតិចក្តាត់ បាសកប្រតិបត្តិសត្វញាតិញោម ។
បាសកកាលនោះស្រុះស្រួលស្រេច ខ្លះស្តាប់គាំងដាច់ទាំងជុះនោម
ពិរោះស្រណោះផ្អើលជៀវចោម ប្រឈមឈរឈប់ម្លប់មុខផ្ទះ ។
ហើយថាមេត្តាប្រាយប្រោសសត្វ ខ្លះខិតចូលជិតគិតចង់ឈ្នះ
លើកហត្ថទាំងសងផ្គងសំពះ សូមមន្តអម្ចាស់ច្បាស់រឿងអ្វី ។
មេត្តាកុំលាក់ជាក់ជាចេះ ទុំមានតម្រិះត្បិតឃើញស្រី
ទាវយកផាហ៊ុមព្រែកម្ទី ដន្លាប់ទិញថ្មីបារីស្លា ។
១០០. បត់បែរតែងស្រាប់ចាប់លើកផ្គង បិទទូលបីដងប៉ងប្រាថ្នា



ថាសូមតេជះព្រះករុណា សូមដូចសទ្ធាចិន្តាផ្សង ។
សូមជួយអោយជួបរូបរូមកាយ កុំអោយឃ្លាតឆ្ងាយដូចបំណង
ជាតិនេះជាតិណាសត្យាប៉ង បានដូចបំណងប៉ងមេត្រី ។
ទាវរៀបផ្គងស្រេចចាប់កាន់ដើរ ដល់មកជិតស្មើនឹងនោស្រី
ថាហកនោបងចូរប្រណី ប្រគេនបារីស្លាផាហ៊ុម ។
អោយខ្ញុំជាគុណជាបុណ្យខ្លះ កុំអោយខ្ញុំខ្វះទ្រព្យចូលជុំ
ជាតិនេះជាតិក្រោយអោយមានធំ កុំបីអោយខ្ញុំក្រតទៅ ។
នេនទុំទទួលគ្រឿងបរិក្ខារ ស្រេចស្រាយយកស្លាឆាន់រួចនៅ
ឈប់អង់បន្តិចសែកប្រេងម្សៅ រំលឹកដល់ទៅមន្តសារិកា ។
១០៥. លិនថោងកវិករំលឹករក សម្តីហៅយកមណីចិន្តា
លូកយកប្រទាលឆាន់នឹងស្លា ស្នូត្រសាគ្រប់សព្វចប់ជាម្តង ។
រួចនេនទុំស្នូត្រស្រូតបង្ហើយ ស្នូត្រហើយនឹករករឿងប្អូនបង
ឃើញត្រង់ព្រាហ្មណោចោរកន្លង នាំកុមារចងនឹងវល្លិ៍វ៉ៃ ។
បណ្តើរដឹកទៅគួរអាណិត ទូញយំគន់គិតថាឱថ្ងៃ
នេះហើយព្រាហ្មណោចោរចង្រៃ វាយក្បៀយហើយណាំមាតាខ្ញុំ ។
ចរចេញចាកចេរពីសាលា អ្នកម្តាយប្រាថ្នារកសន្សំ
បេះផ្លែឈើបានអ្នកបារម្ភ ខិតខំព្រោះកូនស្ងួនមកអាយ ។
កុមារតូចៗដូចនេនទុំ ស្នូត្របានផាហ៊ុមរុំមិនស្រាយ
យកជាបន្ទាល់ទាវមិនស្តាយ ស្នូត្រចប់រាប់រាយរួចភត្តា ។
១១០. បាសកសំពះខ្លះអួតទុំ លំនៅត្បូងឃុំខ្ញុំរក្សា
សុំជាកូនធម៌ខ្ញុំករុណា មេត្តាអធ្យាគលោកប្រណី ។
នេនស្នូត្រស្នូត្រចប់ត្រឡប់សួរ ញោមអើយគាប់គួរត្រូវអាចក្តី
លាអស់ញាតិញោមទាំងប្រុសស្រី ត្បិតថ្ងៃទន់ទាបរយាបយប់[1] ។

១. រយាប = ទាបទៅ. ជិតដល់ : រយាបយប់ = ទៀបនឹងយប់ ។

ត្បិតទុកនេនពេជ្រនៅម្នាក់ឯង ចំបែងចិត្តចែកបែកទាំងគ្រប់
ខ្លាចចិត្តគេដែលផែមិនឈប់ គិតសព្វគេសោតនេនដូចគ្នា ។
នេនទុំនាំហេតុនិយាយប្រាប់ បាសកផងស្តាប់ហើយលាកលា
ចរចុះដើរដល់នេនពេជ្រជា ប្អូនអើយម្ចីម្តាជាដូចដើម ។
ចូលជិតទុំគិតនិយាយលេង អោយពេជ្របានល្បេងអួតទាវផ្តើម
ថានេនពេជ្រប្អូនប្រុសថ្លៃថ្លើម ទុំផ្តើមប្តេជ្ញាសិកាទាវ ។
១១៥. ចាល្អណាស់ណាំប្អូនសំឡាញ់ ឥឡូវបងកាញ់គិតចង់នាវ
ស្តីគេទៅសួរគួរព្រាងព្រាវ អោយដឹងសុំជាវអ្វីបញ្ចាំ ។
ចិត្តទាវអោយនឹងទ្រឹងឈប់រង់ យើងទៅហើយគង់តែដល់ឆ្នាំ
លាលោកគ្រូសឹកត្បិតយើងផ្តាំ ទាវទុកចំណាំនឹងវិលមក ។
នេនទាំងពីរពិតគិតស្រេចហើយ ពុំលង់យូរឡើយនេនទុំភ្លក
ប្រាប់ថាពេជ្រប្អូនល្មមយើងរក ប្រមូលស្រូវយកច្រកការុង ។
លើកដាក់រទេះកុំស្ទេះឈប់ ល្មមវិលត្រឡប់ត្បិតនៅសុង
នៅសុខស្រុកអាយឆ្ងាយអន្លង់ យើងកុំបង្អង់រង់មិនបាន ។
នេនទាំងពីរពិតគិតវិលវិញ ព្រឹកព្រាងចរចេញមិនមានខាន
រួចលាញាតិញោមទាំងប៉ុន្មាន ចរថ្កានដល់ដានដងមាត៌ា ។
១២០. បរកាត់ត្រូវត្រង់បង្អង់ឈប់ នេនទុំជ្រុលជ្រប់ជ្រកវេទនា
គ្រៀមក្រាំខំទប់សញ្ជប់ជា ទុក្ខណាស់ភ្លកភ្លាភរកស្រាយ ។
បង្អេចវេចរុំជុំក្លិនផ្កា ហត្ថាទាញយកមកជិតកាយ
រួចយល់ដើមឈើផងទាំងឡាយ រាប់រាយរៀបរាប់ផ្តាប់តម្រូវ ។
ឱដើមទន្លាប់ទន្លាមក ដើមធ្លកទុំសោកសព្វតាមផ្លូវ
ដើមថ្កាន់បានថ្ងបដល់ឥឡូវ ប្រាសទាវអោយនៅតែម្នាក់ឯង ។
ឱក្លិនផ្កាអ្វីអើដល់ម្ល៉េះ ក្រអូបផ្កាម្លិះឬផ្កាស្លែង
អប់នៅផាហ៊ុមទាវតុបតែង ដាក់នៅខ្នើយចំបែងបង់ ។



ចាកចោលទាវស្រីសេចក្តីទាល់ មិនដែលឃើញស្គាល់ទុំជាសង្ឃ
ហ៊ានកាត់ចិត្តជ្រៀតឆ្វៀតតម្រង់ បូជាផ្ចិតផ្ចង់ភ្ជាប់ប្រាថ្នា ។
១២៥. ដន្លាប់ក្រមួនធូនពាសពេញ ទាវអើយទុក្ខអញម្តេញខ្លោចផ្សា
កើតទុក្ខទៀតថ្មីចារិស្លា ទាវស្រីស្នេហាប្រគេនមក ។
ឥឡូវយល់សត្វច្រវាត់ទុំ ឈ្មោលញីយាសយំហើយហើររក
ចឹកចាប់ផលាប្រាថ្នាយក ដល់កូនចូលជ្រកក្នុងរូងរន្ធ ។
បញ្ចុកកូនគាប់អភ័ព្វអញ ម្ល៉េះទាវគ្មានក្លាញ់ជាទុក្ខធ្ងន់
ទុក្ខមិនថ្ងបស្បើយល្ហើយស្រាក់ស្រន់ បូជាបែបន់ទេវារក្ស ។
សូមសុំប្រាថ្នាថាអោយអញ វិលវិញត្បិតទាវនាងស្មោះស្ម័គ្រ
ឥឡូវអាចក្តីមកឈប់ស្នាក់ ធុរៈក្នុងអង្គស្រយង់យំ ។
ស្រេចហើយនេនពេជ្រគេចហៅថា ទុំកុំសោកាគិតបារម្ភ
ទុក្ខអ្វីស្រីទាវនាងរៀបចំ នរណាហ៊ានបំព្រាត់ទាវទៅ ។
១៣០. រួចយកគោមកទឹមរទេះ បរវេះវាងរកកាត់តម្រូវ
តម្រង់ដោយអានល់អានផ្លូវ បរត្រូវត្រង់ភ្នំជ្រំស្រឡៅ ។
ស្រឡាំងភាំងភិតគិតទៅទៀត ចង្អៀតឱរាផ្សាខ្លោចក្តៅ
ស្រងាត់ស្រងោចស្រងូតសៅ បងមើលឃើញស្មៅស្មាប់ត្រាច់ត្រស់ ។
ឱឈើទាលត្រង់អង្គអញបែក នាងផ្ញើកអញផ្ញុកភ្លកស្រណោះ
ដើមផ្ញៀកអញផ្តាសប្រាសប្លែកសោះ កកោះក្រគិតឥតមានស្បើយ ។
គគីរគគោកដូចរោគអញ ក្លួលក្តៅពោរពេញចុកណែនហើយ
ហៅថានេនពេជ្រសំឡាញ់អើយ ពេជ្រគ្មានឆ្លងឆ្លើយកឆ្លើយទប់ ។
ជាទុក្ខជូសទុំយំទាំងសង ខំថាសាសងទុំអើយឈប់
ចាំដល់វត្តស្ថានបានយូរយប់ យើងគិតគោរពបង្គំលា ។
១៣៥. ទូលលោកគ្រូយើងទុំនើងថា លាសឹកមានការព្រោះវេទនា
កុហកថាញាតិញោមមិនជា កើតព្យាធិរោគាជាទុក្ខធ្ងន់ ។

អ្នកនេនទាំងពីរនិយាយគ្នា    បរស្រូតម្ដីម្នាពារពេលពន់
ទេរទាបត្រជាក់អ្នកគយគន់    មើលព្រះសូរិយ័នក៏ទន់នៅ ។
បៀតបែរបាំងបាត់សត្វចរចូល    ជិតជិះកំពូលគិរីនៅ
ទីទិសបស្ចឹមបែរសំដៅ    ឈ្មោះហៅសុមេរុរាជគិរី ។
បរបានដល់វត្តប្រាកដឈប់    ល្មមពេលព្រលប់ចូលក្នុងទី
ឈប់ឈរដោះគោលែងទាំងពីរ    អោយស៊ីស្មៅខ្ចីក្នុងទីស្ថាន ។
ហើយនេនពេជ្រទុំជំនុំនៅ    នេនផងចូលទៅទាំងប៉ុន្មាន
សន្ទនាសួរគ្នាថាសុខប្រាណ    លក់ដូរតើបានស្រូវឬប្រាក់ ។
១៤០. ឬយកកាក់លុយប្រថុយថា    ប្រាប់ផងករុណាអោយត្រង់ជាក់
ត្រូវចិត្តត្បិតនេនពីររាក់ទាក់    ថាបានប្រឡាក់ប្រឡូកព្រម ។
ជាស្រូវជាស្រីជាល្ហីច្រែង    ជាជ័រជាស្នែងជាថ្នាំងក្អម
ជាឈ្នួតផាហ៊ុមទឹកឃ្មុំល្មម    កន្សែងសោតព្រមតែថ្លៃតោក ។
ហើយនេនគិតគួរពុំយូរលង់    នាំគ្នាតំរង់ឡើងទៅរក
ថ្វាយបង្គំគ្រូជូនជាក្រោក    តើនគង់ឈោងយកទឹកលុបភ័ក្ត្រ ។
នេនពីរក្រាបឱនលំទោនទាប    សុភាពខ្លាចគ្រូទើបតើនភ្ញាក់
បារម្ភក្រែងខ្វាល់លោវាយធាក់    ស្រេចហើយបែរភ័ក្ត្រទតទៅសួរ ។
ពុទ្ធដីកាថានេនពេជ្រទុំទៅ    លក់ដូរដោយនៅតាមសមគួរ
បាសកឯនាយវាឆ្អើងជួ    ឬវាទិញដូរទៅរាល់ខ្លួន ។
១៤៥. នេនឆ្លើយសងសបតបទូលទៅ    ក្រាបទូលបានស្រូវគ្រប់ចំនួន
ចំណេញតោកស្មានជាបីបួន    សមសួនល្មមកែតែគ្រាន់ចាយ ។
នេនក្រាបទូលគ្រូគួរសមគ្រប់    រួចលាត្រឡប់វិលប្រញាយ
ដើរដល់កុដិស្ថានសម្រាន្តកាយ    ប្រះប្រាណនឿយណាយនឹកទាវទៀន ។
ថ្លែងថាអនិច្ចាជាកម្មអ្វី    ទុក្ខកើតជាថ្មីទ្រូងចង្អៀត
លូកយកផាហ៊ុមដែលរុំសៀត    ទុំឆ្លៀតថើថៃប្រែប្រះប្រាណ ។



ក្លិនក្លែបអែបអប់ត្រឡប់ផ្កា    ទុំយកហត្ថាក៏កាន់បាន
យកមកទទូរគ្របគិតស្មាន    ថាបានគ្រាន់តែលំហែទុក្ខ ។
ទុំថាឱផ្កាបុផ្ផាផង    ធរផុំល្អប់ល្អងបងគ្មានសុខ
ផុំផ្ការំចេកដេកមិនលក់    ពិដោរគ្រប់មុខចុកឱរា ។
១៥០. ឱវែងស្រមៃវិស័យនៅ    ជួបពៅជូនបានក្សាន្តចិន្តា
ម៉ែមន្តបងស្មូត្រមទ្រីបាពិ    ប្អូនបានបូជាផ្កាឈើផង ។
បូជាព្រះធម៌ផុំសាយសព្វ    ប្អូនអប់ផាហ៊ុមប្រគេនបង
បូជាពុំងានាងទាវផ្សង    អោយជួបអញផងបងប្រាថ្នា ។
ឥឡូវអាចក្តីឃ្លាតទាវហើយ    ទាវអើយទល់ទុក្ខខ្លាំងខ្លោចផ្សា
ទាវទប់មិនឈ្នះអន្ទះសា    មិនមានហើបហានិយាយស្តី ។
បងអ្នកប្រមាណទាវបាននោ    គាត់[1] ជួយគិតគួរលំហែស្រី
រំលឹកមិនអោយទាវចុះដី    ក្រែងខ្លាដំរីសត្វអ្វីខាំ ។
ឬទាវលួចរត់ប្រាកដមក    តាមបងជ្រុលជ្រកមិនបានផ្តាំ
គ្រាន់តែសំគាល់បន្ទាល់ចាំ    ដោយថ្នាំដោយស្លាដោយផ្កាឈើ ។
១៥៥. ដោយបានបូជាផាហ៊ុមមក    ឥឡូវបងភ្ញាក់គ្រប់អន្លើ
លន្លន់លន្លោចត្រមោចស្មើរ    មិនរស់ទេតើទុក្ខអង្គអញ ។
លង់លុះដល់ដាច់រដូវមួយ    ទុំព្រួយរីងរីតតែស្រឡាញ់
ឃើញអស់កូនគេមកខ្វល់ខ្វាញ់    ពាសពេញចូលវត្តសន្ធតត្រូវ ។
មកបុណ្យមកបួសមកបិណ្ឌភ្ជុំ    មកដល់ជំនុំជាច្រើនផ្លូវ
មករាប់បាត្របូជាតម្រូវ    តម្រង់រដូវចេញវស្សា ។
នេនទុំទុកធំងំគ្មានស្បើយ    ទុក្ខហើយហៅពេជ្រមកប្រាប់ថា
នេនពេជ្រអូនអើយបងឈឺផ្សា    ដូច្នេះប្រាថ្នានៅមិនបាន ។
នេនពេជ្រទទួលស្រួលសងសប    ថាទុំអើយថូបអោយធូរក្សាន្ត

១. ច្បាប់ខ្លះថា បើបានខ្លួនបងនិត្យនៅយូរគ្រាន់ជួយគិតគួរ...

ទំរាំពារពេលយើងប្រមាណ ចូលថ្កានលាគ្រូធូរព្រះទ័យ ។
១៦០. នេនទាំងពីរពិតគិតច្នោះស្រេច បែរគេចយកទៀនធូបឆាប់ខ្មី
ដើរទៅបានដល់ឡើងកុដី ដាក់អង្គគង់ខ្មីក្រាបបីដង ។
អុជទៀនអុជធូបក្រាបវន្ទា សូត្រចប់ចូលលាហើយសាសង
ថាសូមទានប្រោសអត់ទោសម្តង បំណងមកលាព្រះគុណធំ ។
លាចែកលាចាកសិក្ខាបទ សន្ទតព្រះគុណប្រោសយើងខ្ញុំ
ទាំងពីរនាក់នឹងថ្វាយបង្គំ សូមសុំករុណាត្រាប្រណី ។
ត្បិតខ្វល់ដល់ការមានធុរៈ ញាតិញោមដល់ថ្នាក់គាត់កើតអ្វី
រោគធ្ងន់ទុរន់មិនគប្បី ញោមស្រីដល់ស្រែបែរបន់ថា ។
អង្វររកជូរតូខ្មោចព្រៃ ដោយភ័យណាស់ហើយគាត់សច្ចា
សំពះអស់ខ្មោចនៅរក្សា ចំណាំជូនតាបង្ការសព្វ ។
១៦៥. គ្រោះថ្នាក់ជិពាក់ញោមស្រីបន់ ថាអន់អោយខ្ញុំលាត្រឡប់
សឹកទៅអោយជាស្បើយកុំថប់ ជួបចប់ដល់ចាស់ឈ្នះទាំងព្រម ។
លោកគ្រូស្តាប់ជាក់កន្ទ្រាក់ក្តារ ផ្ទួនបូកលេខហារថាតែហោង
កុហកអញទេអាកន្ទ្រម ស្រីចោមស្រូតចោលបោលមកលា ។
អញវាយលេខលុបគ្រប់ជើងហោរ លេខឆ្លើយឡើងថាអាកុំពារ
កុំពុះទម្លុះក្រែងវេទនា ឃើញថានេនពេជ្រគេចគ្រាន់បើ ។
នេនពេជ្រសឹកចុះខែបុស្សបាន ទុំឯងឈប់ខានទើបប្រសើរ
ចាំដល់ពិសាខសិនសឹមដើរ សឹកហើយត្រូវលើបានជាធំ ។
លង់លុះដល់ត្រូវរដូវខែ មិគសិរត្រូវខ្យល់ខ្វល់ជញ្រាំ
រហើរហាល់ដល់នេនទុំ ក្រាបយំក្រំយល់អំពល់ពីរ ។
១៧០. ដំណើរមួយព្រួយប្រាណមិនបានសឹក មួយទៀតព្រួយនឹកទាវនៅទី
នៅទាល់ត្បូងឃុំសមស្រីនី- រាសប្អូនបានគេទេដឹងអើយ ។
នេនទុំនេនពជ្រគេចបង្វិល ថាចាំថ្ងៃសីលក្រោយទៀតហើយ



យើងចេះតែលាណាពេជ្រអើយ ពេជ្រឆ្លើយថាកុំខំមិនបាន ។
នេនទុំទុក្ខងំកើតទៀតថ្មី ស្តាយស្រីស្តាយស្រស់ផ្លស់គ្មានក្សាន្ត
អត់បាយចំណីស៊ីមិនបាន គិចណាស់មួយចានបានបីម៉ាត់ ។
លង់លុះគម្រប់ចប់ជួលជា វេលាខែបុស្សព្យុះខ្យល់ផាត់
រហើយត្រជាក់ភ្នាក់ព្រឺប្រាត់ ផាយផាត់ពពកមកដេរដាស ។
ដង្គោលដង្គំប្រជុំជិត ងងឹតពេញស្ថានដានអាកាស
នេនពីរពង្សពិតគិតច្រឡាស ច្រឡើសមិនខ្លាសផ្តាសជាងគេ ។
១៧៥. នេនពេជ្រចូលលាពារប្រថុយ គិតថាខុសអុយបើលោកជេរ
ឡើងទៅដល់ដាក់អង្គកាយេ លើកហត្ថទាំងទ្វេប្រណម្យនៅ ។
លោកគ្រូសាកសួរគួរវិញថា ពេជ្រសឹកថ្ងៃណាក៏សឹកទៅ
ក្នុងខែបុស្សបានទំនួលត្រូវ សឹកចុះធ្វើស្រូវរដូវស្រួល ។
នេនទុំសម្ងំលបចាំស្តាប់ ពេជ្រគេសឹកឆាប់បានទំនួល
ឮដូច្នេះហើយទុំក៏អាក់អួល ខ្លាញ់ខ្វល់វឹងវីតជញ្ជឹងចាំ ។
រួចថាអញនៅមិនបានឡើយ ព្រះគុណខ្ញុំអើយហេតុតែកម្ម
ជាកាលណានឹងប្រឹងទ្រទ្រាំ ម្លេះសមស្លាប់ខ្លួនមួនមែនពិត ។
មិនស្តាយផ្លូសប្រាណបានប៉ុនសក់ កម្មនាំកញ្ចក់អោយងងឹត
មោហ៍បាំងឆ្នាំងគ្របក្រសោបរឹត គ្មានគិតគ្មានគួរលោកគ្រូខ្វាល់ ។
១៨០. នេនពេជ្រលាសឹកព្រឹកនេះទៅ ទុំនៅក្រៀមផ្អស់ស្មុះទៅគាល់
បណ្ឌិតពេជ្រឃាត់ថាកុំអាល ចាំស្រាលព្រះទ័យភ័យថ្វីពេក ។
យើងស្នេះទុំពេជ្រគេចសម្តែង ស្រីទាវចំបែងវែងវិវេក
កើតទុក្ខមួនមាំក្រំសញ្ញែក រាវែកវីតវឹងទន្ទឹងទុំ ។
ថាឱអញស្តាយក្រហាយប្រាណ មិនក្សាន្តធ្ងន់ខ្លួនប្រៀបហាក់ភ្នំ
រលើងបព្ធតាផ្ការរលំ សង្កត់សៀតក្រំរណ្តំខ្លាំង ។
ខ្លោចផ្សាក្តៅក្តួលខ្វលក្នុងថ្លើម ដង្ហើមផុត១ស្កុតភាន់ភាំង

ម្លេះហើយលោកអើយប្អូនមរណំ ខ្លួនស្ទាំងស្ទាំងស្តមទ្រមវេទនា ។
ពីដូចរូចអ្នកចាកចោលទៅ ទុក្ខខ្ញុំប្អូននៅអោយកំព្រា
កំព្រៀនព្រួយប្រាណពុំបានជា ទាវរារកមើលព្រើលស្រមៃ ។
១៨៥. ហាក់ដូចឮស័ព្ទចាប់ដល់ទុំ លោកស្ទូតស្តាប់ជុំណាំអ្នកថ្លៃ
សូរស័ព្ទសំលេងគួរអាល័យ ទាំងរូបប៉ប្រែប៉ប្រឹមប្រែ ។
សម្បុរយល់ចាប់ប្រដាប់ស្បង់ ត្រចង់ដូចវង្សព្រះច័ន្ទដែរ
ត្រចះភ័ក្ត្រមូលស្រួលដូចខែ ដូតខាត់ដុសបែជាបែកបាត់ ។
ជាបានប្រាណប្រុសមកវិញដែរ ឬមួយជាបែរដោយឈឺថ្កាត់
ធ្វើម្តេចបានដឹងដំណឹងស្ងាត់ ជូលគេអោយស្កាត់វង្កាត់គន់ ។
មិនដឹងជាផ្លូវទៅត្រង់ណា ខ្លួនអើយខ្លោចផ្សាជាទុក្ខធ្ងន់
ពាប់ពៀបដូចទូកដូចទឹកជន់ ដោយទន់ដល់ទៀបហៀបក្សិណក្ស័យ ។
រួចទាវហៅទៅនាងនោថា នែអើយជួយរ៉ាជួយរាប់ដៃ
ជាយូរឬឆាប់ដោយស្រមៃ នោស្មានខែថ្ងៃប៉ុន្មានមក ។
១៩០. នាងនោភិលៀងបញ្ចៀងអោយ ថាចាំខែក្រោយមើលពពក
សាត់ពីទិសទីឭសានជ្រក ពពូនសមភ្នកមកទាវស្រី ។
ខ្យល់ផាត់ត្រជាក់ធ្លាក់សន្សើម ជ្រួលជ្រើមក្នុងចិត្តគិតប្រណី
ប្រឹងនឹកមកទាវចង់បេតី ហេតុអ្វីប្រដល់ទាល់ជាសង្ឃ ។
សព្វថ្ងៃព្រួយដែរតែគ្មានសុខ ម្លេះសឹងមិនលក់ត្បិតបោះបង់
បែរបែកត្បិតបានប្រាថ្នាផ្ចង់ សាងសីលស្មោះត្រង់តម្រង់កាយ ។
តម្រេកទុំគិតចង់ស្និទ្ធស្នេ ហាហេតុព្រោះតែខ្លួននៅឆ្ងាយ
មិនយូរប៉ុន្មានទេទាវអោយ លោកស្រោយសិក្ខាប្រាថ្នាជាក់ ។
កុំទុក្ខទួញយំសុំឃាត់នាង សមគេមិនរាំងកុំផ្ទើលភ្ញាក់
ក្រែងជាមិនជាកើតធុរៈ ដឹងដល់ម្តាយជាក់ជេរផ្តាសា ។
១៩៥. ថាកូនមិនសុទ្ធពុតដូចគោ សន្តានគេហ៊ោគេសើចថា
កូនមានពូជពង្សមានវង្សា ព្រោះឥតកិរិយាស្រីចង្រៃ ។
ហៅបងរំលឹកកុំនាងខឹង បងនឹងទទឹងទេណាថ្លៃ
នឹកធ្លាប់ដឹងចិត្តមកសព្វថ្ងៃ វិស័យដូចពាក្យបុរាណថា ។
ធម្មជាតិជានំគេផ្តុំបាន ដាក់ក្នុងនាឡិចានតាមចិន្តា
មិនដែលនំធំលើសប៉ុនណា ទាវអើយបងមហាថប់ថៃធួន ។
ក្រែងគេមិនមករកទាវទេ ទាវប្អូនកុំជេរបងក្រែងជួន
រំលឹកទៅចុះក្រែងគ្រោះខ្លួន ត្បិតអីឮងួនគេកូនគុំ ។
សមគេជាកូនចៅហ្វាយស្រុក បុណ្យគេធំស្តុកនាម៉ឺនជុំ
ឈររក្សាខេត្តខាងត្បូងឃុំ ទុំរាស្ត្រទាំងផ្តាសដូចគេឯង ។
២០០. បងប្រាប់ទាវទៅពៅកុំអាក់ កុំអន់ថ្នាំងថ្នាក់ចិត្តចំបែង
មិនបានប្រមាណទេទុំស្វែង មកដល់មិនលែងកន្លែងស្រាប់ ។
ទាវឆ្លើយថាមែនដូចនោថា នោមានប្រាជ្ញាវៃចំណាប់
ថាត្រូវសមទុំមកដល់ឆាប់ នោប្រាប់អរព្រឹសលើសសព្វដង ។
ដឹងហើយទាវស្បើយប្រាណបានតិច ប្រះប្រាណដេកធ្មេចលក់ជាម្តង
លុះភ្ញាក់ព្រើតប្រឹងរំពឹងបង អុជទៀនធូបផ្សងដល់នេនទុំ ។
ស្នេះរឿងទាវទៀតឆ្លៀតសម្តែង ដំណើរទុំតែងយកផាហ៊ុម
គ្របគ្រងកាយាពិដោរជុំ ក្រអូបពិតពុំមានរសាយ ។
លុះជួបជូនយប់យន់ស្ងប់ស្ងាត់ ព្រួចព្រឹប្រមាត់រន្ធត់កាយ
រន្ធត់ថៃថប់ជ្រប់ខ្វល់ខ្វាយ មិនស្តាយចង់សឹកនឹកទាវស្រី ។
២០៥. ព្រឹកព្រាងឡើងច្បាស់ព្រះសូរ្យសែង ចាំងចែងពីបូព៌ារស្មី
ចំហាយដល់អង្គពុំលង់ខ្ចី ទុំចុះដល់ដីដើរចេញទៅ ។
លង់លុះបានដល់សកលស្ថាន ផ្ទះម្តាយទុំបានជូនជួបនៅ
ម្តាយសោតយង់យល់កូនដល់ទៅ គ្រេកអរចៅរ៉ៅចុះម្ទីម្ទា ។
មកពិតទូលថានេនបាបុត្រ មន្តមកពីកុដិផ្ទើរណោះណា

ចុះកូនពន្លកមកនេះជា ទុក្ខព្រួយវេទនាឬសុខសាន្ត ។
នែនទុំយំយែកទឹកភ្នែកស្រក់ គិតភូតកុហកព្រោះមិនក្សាន្ត
ចំរើនពរញោមឆាន់មិនបាន អាចក្តីប្រមាណប្រាណមិនស្រួល ។
ឆ្អៀបឈឺក្នុងពោះលោះថ្ងៃតិច ដូចគេខ្វារក្តិចស្មានដូចមូល
ដូចម្ជូត្រសំបោរក្តៅខ្លាញ់ខ្នួល រំដួលព្រឺព្រួចរួចខានសឹង ។
២១០. នឹងផ្ចេចមិនលក់ទេញោមអើយ ពូកកែបកល់កើយដេកស្កកស្កឹង
ប្រះប្រាណដល់ខ្មើយជំលើយរឹង ដូចខឹងខំអត់សង្កត់ទុក្ខ ។
អាចក្តីជំណាលកាលថ្ងៃមុន ឡើងលាព្រះគុណគ្មានមើលមុខ
ពិតថាមិនស្រួលមូលសៀតចុក ថាខ្លួនមិនសុខមិនសូវជា ។
លោកគ្មានបើកសោះបណ្តោះពេជ្រ ឯងទូលដូចម្តេចលោករាំងរា
ឃាត់ទុកធ្វើអ្វីអោយវេទនា ញោមទៅបំពារលាអោយផង ។
មេម៉ាយម្តាយទុំយំតាមកូន គាត់ក្រាបអង្គឱនហើយសាសង
ថាម្ចាស់ម្តាយអើយកូនសព្វដង មិនដែលមានហ្មងឆ្គងនឹងអ្វី ។
លោកគ្រូរាប់អានជាងគេគាប់ ប្រគល់អស់ទ្រព្យទោះចាស់ថ្មី
អោយបាថែទាំស្លាបារី បាយទឹកចំណីស៊ីតាមចិត្ត ។
២១៥. ចុះមានបើហេតុម្តេចម្តងណេះ ម្តាយវែងត្រេកត្រិះគួរអាណិត
អាសូរកូនគួរស្មើជីវិត ឥឡូវទុក្ខឥតនរណាដឹង ។
ពីតូចដល់ទុំធំម្ល៉េះហើយ កូនអើយម្តាយព្វតែដំណឹង
ដំណាលទៅចុះក្រែងខុសផ្សើង បើម្លឹងធ្វើម្តេចសុំម្តាយទៅ ។
នែនទុំព្នម្តាយរសាយទុក្ខ ធូរអង្គបានសុខសាន្តដោយនៅ
ដោយអ្នកម្តាយស្រីគាត់ស្តីត្រូវ តាមផ្លូវខុសខូចរួចទុំលា ។
ថាញោមអាចក្តីទៅវត្តឋាន ញោមតើថ្មើរម៉ានឆាប់ម្ល៉ឹម្ល៉ា
រួសរាន់ប្រញាប់កុំវេរា ទាន់អាចក្តីជាអន់អង្គប្រាណ ។
ហើយមួយស្មានដូចខ្មោចដូនតា តែងនៅរក្សាទាំងប៉ុន្មាន



ដូច្នេះជួយផងបើម៉ែបាន ទៅលាគ្រូក្សាន្តស្រួលព្រះទ័យ ។
២២០. មេម៉ាយម្តាយទុំសញ្ជឹងគិត យល់ដោយគំនិតរហ័សវៃ
លូកហត្ថាចាប់ម្លូស្លាខ្ចី ទៀនធូបយកស្បៃដណ្តប់ដើរ ។
ចរចុះល្វត់ល្វន់ស្រទន់ស្រេច ទើបគាត់ចរត្រាច់ចូលទៅស្មើ
នឹងគ្រូសូត្រមួយអង្គគ្រាន់បើ ថាយើលោកម្ចាស់ខ្ញុំខ្មាសគេ ។
អ្នកផងអឹងកងទាំងក្មេងចាស់ គេសរសើរណាស់ឥឡូវប្រែ
ព្រះទ័យព្រះគុណមិនធ្ងន់ដែរ ថាលោកគ្រូកែគិតបទណា ។
នែនទុំកូនខ្ញុំថ្វីលោកម្ចាស់ គាប់ណាស់ម្តេចគួរលោកមេត្តា
កូនខ្ញុំទៅប្រាប់ដល់ម្តាយថា លាចាកសិក្ខាសញ្ញាកូន ។
ជាអកុសលតម្កល់ទប់ មិនបានជាឈប់នៅសុខសូន្យ
ជាសាមណេរទេណាំលោកប្អូន ដោយខ្លួនជាស្រីសេចក្តីទាល់ ។
២២៥. ទើបនាងម្តាយទុំបង្គំលា ចាកទីនោះណាលីលាដល់
ឡើងកុដិលោកគ្រូបង្គំគាល់ លើកហត្ថតម្កល់លើសិរសា ។
ហើយពិតថាខ្ញុំសូមក្រាបទូល បើគួរមិនគួរប្រោសករុណា
ប្រណីខ្លួនស្រីឥតសិកា[1] ចេះអ្វីហ៊ានថាវាចាជួស ។
នែនទុំកូនខ្ញុំមន្តទៅដល់ ផ្ទះហើយមិនសល់ថាទ្រាំផ្នួស
ចង់ចាកសិក្ខាប្រាថ្នាបួស នៅយូរក្រែងជ្រួសជ្រលួសលេង ។
អោយខុសថ្លោះធ្លោយដោយខ្លួនពាល នៅស្រាលតម្រេកពេកនឹងល្បែង
ខ្ញុំម្ចាស់ព្រួយណាស់មួយគិតក្រែង ចំបែងឈឺមួលមិនស្រួលខ្លួន ។
មែនឬព្រះគុណធ្ងន់ដូចថ្ម ក្រែងអោយឆាន់ស្ករនំចិនយួន
នោមយប់ថាស្ទះធូរដោយជូន ជុះយប់ដេកពួនពុំបានសោះ ។
២៣០. លោកគ្រូពុំយូរមានពុទ្ធដិកា ថាទេសិកាទុំកម្លោះ
លាទៅលក់តោកក៏ដាច់អស់ មកដល់ក្រៀមក្រោះស្រណោះស្រី ។

[1]. ច្បាប់ខ្លះថា ខ្ញុំជាសិកា

ខាងខេត្តត្បូងឃ្មុំក្រមុំច្រើន    សៀបស្រស់ស្រវើនក្មេងលីវថ្មី
ឥឡូវចចើងចង់បានប្តី    ហេតុហ្នឹងអាចក្តីយល់ពុំគាប់ ។
ពុំគួរបណ្តោយអោយសឹកទៅ    វាយលេខឃើញត្រូវពានលើងាប់
ទំនាយនេនទុំថាអភ័ព្វ    ឃាត់ជាប់ទំរាំដាច់ឆ្នាំហ្នឹង ។
នាងជាមេម៉ាយម្តាយនេនទុំ    ស្តាប់លោកគ្រូធំគន់សម្លឹង
សម្លក់មកគាត់ឃាតរឹតរឹង    ពុទ្ធដិកាក្រញ៉ឹងដូចខឹងខ្លាំង ។
រូចគាត់លាចុះមកដល់ដី    ថាកូនពិសីកុំតតាំង
ទល់តបធ្វើម្តេចប្រៀបដូចច្បាំង    ត្រូវដូចបាំងអាងកាំភ្លើង ។
២៣៥. តែលោបាញ់បាត់មិនបាត់ស័ព្ទ    ទៅត្រូវសត្វស្លាប់ដូចខ្លួនយើង
បើលោទាយថាផ្ការលើង    រលំបាក់ជើងដួលដល់ស្លាប់ ។
ហេតុនោះឈប់ទៅឬពៅម្តាយ    បើក្តៅក្រហាយកូនក្រឡាប់
ក្រឡេតរកទឹកផឹកលុបឆាប់    ស្រង់ស្រស់រូចចាប់ចារសរសេរ ។
រៀនសូត្រធមិអាចិធ្វើការអ្វី    ចរចេញពីក្តីទើបឋិតឋេរ
ប្រៀបដូចសំពត់រហែកដេរ    ប៉ាក់ថ្មេររៀបចំខំបោសឋាន ។
ទើបនេនទុំឆ្លើយថាណ្ហើយឈប់    ញោមកុំប្រៀបសព្វទប់មិនបាន
អញ្ជើញទៅផ្ទះប្រេះសម្រាន្ត    ញោមទ្រាំកំសាន្តកុំសោយសោក ។
ចាំមើលដល់ព្រឹកនឹកថ្មីទុំ    យកតែផាហ៊ុមទាវអោយមក
ដើរទៅចូលព្រៃប្រាស្រ័យជ្រក    ស្វាត់ហើយទុំក្រោកឈរវន្ទា ។
២៤០. ថ្វាយបង្គំព្រះសំពះគ្រូ    ផ្លាស់ស្បង់ពុំយូររូចលីលា
សីមចរចូលទៅក្នុងព្រះវិហារ    ស្មាលាទោសទុក្ខមុខជាបាប[១] ។
នេនទុំជំនុំតែនឹងម្តាយ    ក្រហាយក្នុងខ្លួនដូចឈឺដាប
ឈឺហ្នឹងឈឺចិត្តឆ្អិតមិនសាប    សូមក្រាបលាកលាឃ្លាឃ្លាតហើយ ។

១. ច្បាប់ខ្លះថា ចូលព្រះវិហារហើយស្មាលាទោសទុក្ខនានាដែលជាបាប ។



ព្រះគុណថ្លៃខ្ញុំកុំប្រកាន់    កុំយកទោសឆាន់ករុណាឡើយ
សូមស្មោះពិតស្មោះដោះអោយស្បើយ    ដល់ត្រើយផុតទុក្ខទៅមុខទៀត ។
នេនទុំគិតស្រេចគេចស្មោះភ្លឹង    ម្នោម្នះដោយខឹងលះស្លង់ស្បៀត
ចាប់យកសំពត់ផ្លត់វេចសៀត    កណ្តៀតដើរដល់យល់ព្រៃធំ ។
សូមសូនពូនជ្រកយកបណ្តា    ភ្ញីផ្កាទៀនធូបចំណីនំ
បូជាទេវស្រេចនេនទុំ    ផ្គងផ្តុំលើកហត្ថប្រណិប័តន៍ថ្វាយ ។
១៤៥. សូត្រថា ឱកាសសត្តេ    កាមំកាមេ នៅដែនអាយ
ចរូបេ ប៉ងបំណងកាយ    តិរិ សឹកស្រាយមិនស្តាយសោះ ។
វន្ទាវន្ទៈអ្នកកុំឃាត់    ផ្លាស់ស្បង់ចោលម៉ត់មិនស្រណោះ
រូចស្លៀកសំពត់ហូលល្អស្រស់    លើកអស់អង្សែកដាក់ទុកទើរ ។
ព្រឹក្សាប្រគាបទាបជិតដី    បណ្ឌិតទុំថ្មីគាត់ហ៊ានធ្វើ
សឹកស្រេចចរត្រាច់ដើរលលើ    អំពើពុតខូចមិនរូចខ្លួន ។
ដើរដល់សកលឋានបន្តិច    វេះវាំងរកពេជ្រស្រេចជូបជូន
បណ្ឌិតពេជ្រសើចហើយជ្រកពួន    ទុំចាប់អង្រួនអង្រន់លេង ។
គ្រានោះពុំលង់រង់យូរថ្ងៃ    ទុំនឹកអាល័យទាវហើយឈ្វេង
ជ្រុលជ្រប់ស្រយុតស្លុតវង្វេង    នឹកណាស់កន្លេងកន្លែងដែល ។
២៥០. ស្រមៃដូចហាក់ភ្ញាក់ប្រវ៉ា    ចាប់ដៃសិកាថាប្រហែល
ដូចទាវនាងសាវធំគ្រាន់ក្រៃល    ដំណែលដំណើរទេណាំស្រី ។
ស្រណោះស្រស់នួនស្ងួនស្តាប់បង    ស្ងួត្រអោយអ្នកផងញាតិនៅដី
នៅដែនត្បូងឃ្មុំជុំថ្មី១    មិនមានភ្លេចក្តីស្និទ្ធស្នេហា ។
បណ្ឌិតទុំទើបនឹងសឹកថ្មី    ប្រាប់ពេជ្រថារ៉ីពេជ្រខ្ញុំថា
អោយប្អូនអាណិតត្បិតបេក្ខា    ចិន្តាប៉ុនប៉ងបំណងនឹក ។
ភ្ជួកដល់ស្រីទាវនាវទុកស្រាប់    បានអោយដន្លាប់ទើបរលឹក
សំពត់ផាហ៊ុមធំក្លិនភ្លឹក    រាល់ពេលយប់ព្រឹកទាន់សឹកហើយ ។

បណ្ឌិតពេជ្រប្រុងរង់ចាំស្តាប់    ឆ្លើយថាខរ៉ាប់[1] មែនទុំអើយ
បើថ្មោះទុំដើរពុំទាន់សៀយ    ទៅឡើយព្រោះខ្លួនមួនមិនសុខ ។
២៥៥. នៅទោសត្បិតអីឯងមានថ្នាក់    គ្រោះបួសជាងជាក់ជាកុលបុត្រ
គ្មានជឿព្រះគុណធ្ងន់បំផុត    ហ៊ានរត់ទៅសឹកមិននឹកស្តាយ ។
ទុំថាបើថ្មោះពេជ្រជូនទៅ    យើងរកគ្រឿងគ្រៅភោជន៍ទាំងឡាយ
ប្រគេនលោកគ្រូលាទោសស្រាយ    ទើបបាត់ក្រហាយក្នុងព្រះទ័យ ។
បណ្ឌិតពីរពិតគិតឃើញស្រេច    ចរត្រាចទៅផ្ទះរូសរាន់វៃ
រកអស់ភោជ្យផលផ្លែឈើព្រៃ    បានស្រេចទុំស្តីពេជ្រជូនដល់ ។
ចូលដល់ក្នុងឋានបានឡើងកុដិ    លោកគ្រូគង់ផ្តត់ផ្អែកខ្នើយខ្ពល់
ទុំពេជ្រដាក់អង្គលើកករកល់    ភ្ញុំភ្និត[2] ផ្ទឹមផ្ទាល់លើសិរសា ។
លោកគ្រូឆ្មៀងភ័ក្ត្រជាក់ប្រាកដ    ថាទុំកម្សត់មកមានការ
រកអញថ្វីទៀតមារយាទអា    ឈ្លើយចុះមិនថាធម្មតាសង្ឃ ។
២៦០. មិនដែលគ្រូណាផ្តាសាសព្វ    មិនមានខឹងស្អប់លោកស្មោះត្រង់
បើសិស្សរអិលល្បៀងផ្សៀងតម្រង់    តម្រែក្នុងអង្គប្រុងប្រដៅ ។
អោយកើតកេរ្តិ៍យសខ្ពស់ក្រដាច    បើសិស្សណាខ្លាចហើយល្ងង់ខ្លៅ
លោកប្រឹងបង្ហាត់កុំអោយឆៅ    រកហៅរៀនសូត្ររហូតចេះ ។
ពេជ្រទុំប្រណមក្រាបស្តាប់គ្រូ    ប្រដៅគ្រប់ផ្លូវនៅកកេះ
ក្រចកដកកអៀនស្រមេះ    រួចរិះឆ្លើយឆ្លងសងពុទ្ធដីកា ។
សូមទានយើងខ្ញុំសុំទោសទុក្ខ    ប្រោសប្រាណទៅមុខទ្រង់ករុណា
ព្រះគុណអត់អស់នូវទោសា    មេត្តាគង់កេរ្តិ៍ថេរៀងទៅ ។
ខ្លួនខ្ញុំខុសឆ្គងហ្មងម្តេចក្តី    សូមសុំព្រះទ័យប្រោសអោយនៅ
ជាសិស្សព្រះគុណទុកជាខ្លៅ    ដោយក្តៅតណ្ហាសង្សារសត្វ ។

១. ច្បាប់ខ្លះថា ឆ្លើយឆាប់ថាអើ
២. ច្បាប់ខ្លះថា ផ្គុំដៃ



២៦៥. លោកគ្រូមានពុទ្ធដីកាឆ្លើយ    ថាអើមែនហើយដូចឯងកាត់
ស្តីនោះចំពោះត្រូវពេញមាត់    ប៉ុន្តែប្រយ័ត្នថ្កាត់ដល់ខ្លួន ។
អញអត់ទាំងអស់ទោសចាស់ថ្មី    ក្នុងនាលោកិយកុំអោយជួន
ទុក្ខពីមុនមកនឹងជ្រកពួន    មិនរួចត្បិតក្បួនច្បាប់ប្រាប់ច្បាស់ ។
ព្រះអង្គសំដែងតែងមានទុក្ខ    ក្សិណប្រែជាសុខរៀងដល់ចាស់
ឯថ្នាក់មរណាំតាំងស្រឡះ[1]    ព្រះពុទ្ធដីកាព្រះត្រាស់ទេសនា ។
បណ្ឌិតពេជ្រទុំបង្គំនៅ    ចាំស្តាប់ប្រដៅព្រះពុទ្ធដីកា
លោកគ្រូអាណិតសិស្សសូត្រថា    កត្តាវត្ត បទទាំងបី ។
ពរព្រះជាម្ចាស់ទុកទូន្មាន    សត្វណាស្រេកឃ្លានទាំងប្រុសស្រី
ធម្មតាកើតមកក្នុងលោកិយ    សួស្តីមង្គលយល់ស្រាប់ហើយ ។
២៧០. ពេជ្រទុំប្រណម្យស្តាប់លោកគ្រូ    សូត្រចប់អោយពរទទួលឆ្លើយ
ថាសាធុសូមអោយបានស៊ើយ    ល្ហែល្ហើយអោយពរអរទទួល ។
លើកហត្ថប្រណិប័តន៍ផ្តុំទាំងសង    ក្នុងចិត្តប៉ុនប៉ងត្រូវទំនួល
ដំណើរលើខ្លួនត្រេករំជួល    ស្រាកស្រួលព្រឺសព្រឺធ្វើហាក់រាយ ។
ទើបទូលលាលាកថាសូមសុំ    ព្រះគុណប្រោសខ្ញុំត្បិតនិយាយ
នឹងអស់បាសកនៅស្រុកនាយ    រួចរាយរាល់គ្នាថាអោយទៅ ។
សន្ទតប្រាកដមិនអោយខាន    សន្ធានផ្តាំនោះចំពោះត្រូវ
ប្រមាណបណ្តាក់តោកជាស្រូវ    អង់នៅក្រែងខុសអស់សញ្ញា ។
បាសកត្បូងឃុំទទឹងថ្ងៃ    ពួនពឹងអាស្រ័យព្រៃបន្លា
នូវមន្តអាគមវិជ្ជាការ[2]    ខ្មោចព្រាយអ្នកតាតោបាច្ឆប់ ។
២៧៥. ហើយមានតម្រិះចេះសុខុម    វាគិតផ្សំផ្គុំទុំអោយឈប់
ផ្តងនឹងនាងទាវទើបចូលម្លប់    យើងខ្ញុំដូចស្អប់វេះវាងមក ។

១. ច្បាប់ខ្លះថាក្រែលក្រាស់ ។
២. ច្បាប់ខ្លះថ គេមានអាគមមន្តគាថា

លោកគ្រូផងស្តាប់ស័ព្ទទុំពេជ្រ ឆ្លើយគេចកែថាឯងគិតភ្លុក[1]
មិនមែនទេតើអាកំព្រក ធម្មតាទុក្ខសោកសព្វបណ្តា ។
មនុស្សក្នុងលោកិយទាំងស្រីប្រុស មិនដែលស្ងប់អស់ស្រីទេណា
កុំភូតកុហកអញដឹងការណ៍ ប៉ុន្តែមិនថាដូចផ្ញុំផ្ទាល់ ។
ហើយឯលោកគ្រូគួរគិតអោយ បណ្តោយតាមចិត្តមិនមានសល់
ថាអាទៅចុះកុំខ្លាយខ្វល់ ខ្លួនទាល់ស្គាល់គេអោយថេរលង់ ។
កុំអាងប្រាជ្ញាក្លាគ្មានកោត ខ្លាចគេចាក់ដោតព្រោះខ្លួនផុង
ស្រដីមិនកោតគេពូជព- ង្សាវតាគេគង់ប្រុងកិរិយា ។
២៨០. កុំអាទាហ៊ានរានទីទៅ ដឹបួចកូនចៅគេផ្តាសា
ប្រពន្ធគេធំកុំរិយអា ប៉ុនប៉ងប្រាថ្នាស្រវាចាប់ ។
ប្រកៀកប្រកាន់កំណាន់នឹង ធម្មតាស្រីរឹងចង់ដោយឆាប់
វារកកម្លោះថ្លោះចំណាប់ ប្រញាប់ទាន់ចិត្តឥតគិតក្រែង ។
ដំណាលដំនៀលដល់មកគ្រូ អង្គព្រះសព្វញ្ញូទ្រង់សម្តែង
ថាបាបដរាបដាច់សង្វែង ផុតលែងកបកើតកំណើតទៀត ។
ឯអញគ្រូឯងអត់ទោសា មិនប្រកាន់ថាអោយចង្អៀត
អញអោយពរអ្នកចូរបែរបៀត មកគ្រូនឹងឆ្លៀតសម្តែងធម៌ ។
លោកគ្រូកាន់ផ្ចិតបិទព្រះភក្រ្ត សូត្របានពួជាក់អោយត្រេកអរ
អាយុវណ្ណំ សុខស្មោះស សុខំ អោយបរិបូរណ៍បានបុណ្យ ។
២៨៥. ពលាពលំ ទាំងពីរនាក់ អោយមានយសសក្តិប្រាក់ទ្រព្យធន
កម្លាំងប្រាជ្ញាមិនអាប់អន់ ប្រពន្ធក្រមុំព្រហ្មចារី ។
កេរ្តិ៍ឈ្មោះល្បីល្បាយសាយអំណាច អ្នកផងកោតខ្លាចទាំងប្រុសស្រី
នៅចុះព្យាបាលទាំងទឹកដី ស្រុកស្រីទាវនៅទៅអោយបាន ។
កូនសិស្សបណ្ឌិតពិតពីរពេញ អម្តេញពេញម្នះអស់ពីប្រាណ

ឥតអ្វីយកមកប្រៀបប្រមាណ ស្មោះស្មើដូចបានស្ថានសួគ៌ា ។
ស្រេចហើយបណ្ឌិតក្រាបស្តាប់គ្រូ លោកគ្រូអោយពរអភិវា[1]
អភិវាទលើកហត្ថបង្គំលា ចរចុះម្ទីម្នាដើរចេញទៅ ។
ឡើងដល់លើផ្ទះដាក់អង្គកាយ ស្រដីប្រាប់ម្តាយថាឥឡូវ
អ្នកម៉ែយើងនេះសន្មតថាត្រូវ ដោយនូវដំណើរតើអ្នកម្តាយ ។
២៩០. ជាបើកអោយកូនឬអ្នកឃាត់ ត្បិតជួបសន្មតយើងឯអាយ
គេថាបើបានសុខក្នុងកាយ សប្បាយជានាថាអោយទៅ ។
ម្តាយអ្នកបណ្ឌិតគិតចង់ឃាត់ ទើបគាត់ស្រដីថាកូនពៅ
ម្តាយនេះសព្វថ្ងៃដូចមិនសូវ សុខសាន្តដោយនូវត្រូវរោគា ។
ចាស់ខ្លួនជូនដល់កុសលត្រូវ នឹងពឹងរកហៅញាតិផងគ្នា
មិនដូចជាកូនស្ងួនពុំងា ម្តាយនឹងរាំងរាពេលាបាន ។
ថាកូនប្រាកដសន្មតត្រូវ អ្នកនឹងចេញទៅនឹងឈប់ខាន
វាបង់នាទីពីបុរាណ កូនស្មានប្រយ័ត្នណាំថ្លៃម្តាយ ។
ទើបឯបណ្ឌិតពិតពីរប្រាណ អរបានដូចគ្នាទាំងពីរកាយ
ស្មោះសត្រេកអរពេកអម្បាយ ក្របាយដូចម្តេចក៏គេចហើយ ។
២៩៥. បណ្ឌិតពេជ្រទុំជំនុំគ្នា បែរភក្ត្រានិយាយឆ្លាស់ឆ្លងឆ្លើយ
ថាយើងទៅដើរសម្លាញ់អើយ ពេលពន់នៅឡើយមិនទាន់រក ។
ថ្មើរមាណដើរបានប្រាណមានជ័យ មានលាភគ្មានភ័យពេលាជោគ
សិរីទ្ធិយាឬតាមលោក ទាំងពូងបែងបូកយកស្លោកសូន្យ
កាកបាទមិនស្អាតខាតទ្រព្យា ចេញដើរខុសពារវេទនាខ្លួន
ដើរត្រូវសូន្យពីរឬសូន្យបួន ចរជូនលាភៈជាក់ប្រាកដ ។
បណ្ឌិតពីរពេញស្រឡាញ់ពេល ប្រហែលចេញដើរដោយសន្មត
ពេលព្រឹកភ្លឺស្វាងបំព្រោងព្រាត់ ទើបគាត់ទាំងពីរលើលាចេញ ។

១. ច្បាប់ខ្លះថា ឆ្លើយគេចកែថាឯងលៃលក

១. ច្បាប់ខ្លះថាតូពីរអង្គា

ចាកចរជួបផ្លូវត្រូវវាលស្រែ
គំនាប់សន្ទានទាំងពួងមិញ
៣០០. ក្រាបលាវាល់គ្នាទៅត្បូងឃ្មុំ
ចោលស្រុកភូមិស្ថានទេវិលថ្វាត់
អាណើតគាត់ផងបងប្អូនស្រាប់
ក្រែងមានធុរៈរោគមកផ្សំ
សន្ទានទុំពេជ្រគេចឆ្លងឆ្លើយ
បែរខ្វាកចេញចាកវិលរួសរៀវ
ទើបឯបណ្ឌិតពីរលិលា
ដើរហើយអស់ឯកនឹកភូមិឃុំ
ទើបទុំដល់ជ្រៃឈើរបោះ
ស្រក់ស្រោកទឹកភ្នែកនឹកឆោមស្និទ្ធ
៣០៥. មកយល់វាលវែងត្រែងដូលដុះ
ដូចរូបសម្បុរពណ៌កនិដ្ឋា
មៀងមើលទឹកជ្រៅស្មៅត្រកៀត
ត្រកួនដូចខ្លួនបងឈប់ដេក
យាប្លូងដូចបងភ្លាត់ឃ្លាតឆ្ងាយ
ស្រងេះស្រងូតរហូតវៃ
ហើយអ្នកពីប្រាណបានដល់ព្រៃ
ទុំរាប់ដើមឈើប្រើបណ្ឌិត
បេះផលពិសីស៊ីពិសា
ផ្លែពួចដូចពេលទាវនាងហ៊ាន
៣១០. មើលមានផ្លែចន្ទន៍សិរមាន់ព្រីង
សង្ស័យស្រមៃមិនបានថា
យល់ញាតិដើរហែងាកវិលវិញ
មីងមាថាអញខ្ញុំប្រណិប័តន៍ ។
មីងអើយកុំយំខ្ញុំមិនកាត់
មីងមាកុំផាត់ទាត់ម្តាយខ្ញុំ ។
តាមដោយសណ្តាប់ជួយថៃទាំ
ក្រាលក្រំចុកញាត់ហាត់ហឺតហៀវ ។
ថាអីក្មួយអើយមុខទ្រង់ខៀវ
ទុក្ខទាវដូចទឹកនឹកដល់ទុំ ។
ធ្លាក់ដល់មាតាស្រុកត្បូងឃ្មុំ
ពេជ្រទុំរិះរែងចម្បែងចិត្ត ។
នឹកដើមស្រណោះឆ្អល់ឆ្អែតឆ្អិត
ទាវអើយបងគិតឥតឧបមា ។
ផ្កាសត្រសុសផ្លែកភ្លឺថ្លា
ដូចផ្កាត្រែងត្រស់ស្រណោះពេក ។
ចិត្តបងចង្អៀតរីងរិវេក
ឈប់ដោយម្លប់មែកត្របែកព្រៃ ។
ព្រៃព្រួយមកអាយយូរឃ្លាតឃ្លៃ
ម្ល៉េះសមប្អូនភ័យមមៃគិត ។
ដល់ព្រឹករំពៃព្រួយរីងរិត
ពេជ្រអោយឈោងឃើតត្បិតស្រេកឃ្លាន ។
ទុំនឹកដើមថាពេជ្រអើយមាន
នាងហាក់ដូចមានចិត្តចេតនា ។
ដូចទាវស្រីឈ្ងៀងនឹកសង្សារ
ដូចចន្ទផលាផុតចាកឆ្ងាយ ។



ស្រគំស្រគត់រលត់ធាតុ
យល់ស្វាទាំងហ្វូងលោតប្រញាយ
សម្តែងវាចាថាប្រាកដ
ជាបងឃ្លាឃ្លាតសង្វាតខ្ចី
បងមើលមានផ្លែឈើទុំខ្ចី
ង្សារសាច់ចរត្រាច់ស្មោះតម្រង់
បងមើលគុណគាប់ប្រថាប់ផ្លែ
របស់បញ្ចាំផ្តាំទុំពេជ្រ
៣១៥. នៅឆ្ងាយវាលវែងចម្បែងចិត្ត
សត្វរីតតែយំទុំមមៃ
ល្ងាចហួសជ្រលជ្រួសវង្វេងផ្លូវ
នៅលង់ក្នុងព្រៃរុំពេជ្រអើយ
ពេជ្រឆ្លើយថាអើបើដូច្នោះ
ប្រយ័ត្នក្រែងមានខ្លាក្រាបពួន
ដើរមកឈប់ជ្រកពុំគប្បី
ពេជ្រទុំជំនុំក៏គិតស្អាត
លុះឡើងដល់មែកល្មមដេកបាន
ពួសួរសត្វយំទុំសម្លំ
៣២០. ក្រឡេកក្រលៀងឆ្មៀងមើលព្រះ
ម៉ោង១០យន់យប់យូរជ្រៅក្រែល
ព្រះពាយផាយផាត់ស្វាត់ត្រជាក់
ស្រប់ស្រស់ចុះចំបំព្រំជោក
សូរស័ព្ទសព្វស្រងាត់យំ
បណ្ឌិតពេជ្រទុំបារម្ភក្រែង
ព្រួសព្រើលមារយាទមើលយល់ស្វាយ
ព្រោះញាតិនៅឆ្ងាយចាយសម្តី ។
នាវនាងទាវបទបានហេតុអ្វី
គោគេវិលវៃបែរបែកបង់ ។
ស្វាយព្រៃស្វាយព្រាតដូចឃ្លាតស-
តម្រេតក្នុងអង្គផ្ចង់មិនភ្លេច ។
ប្រៀបដូចទាវស្នេហ៍មិនបែរគេច ។
ឥឡូវចរត្រាច់មិនលេចព្រៃ ។
ចំជាបងគិតត្បិតសត្វរៃ
មមាលឧទ័យថ្ងៃល្ងាចហើយ ។
ដើរពានត្រង់ត្រូវឬនៅឡើយ
រកថ្ងបផ្អែកកើយលំហើយខ្លួន ។
យើងរកចន្លោះណាមាំមួន
ខាំខ្លួនអសារជីពជន្មជាតិ ។
ព្រោះស្រីព្រួយស្រើបទើបឱហាត
ឡើងចង្អូរត្នាតឃ្នាតខិតខំ ។
ប្រះប្រាណមិនមានព្រួយបារម្ភ
រៀបចំប្រុងប្រាណប្រមាណពេល ។
ចន្ទចែងភ្លឺច្បាស់រះប្រហែល
នឹកដែលនឹកដល់ស្រងល់ងោក ។
រហើយដល់ធ្លាក់សន្សើមស្រោក
ជាប់ជាំដើមធ្លកឱ្យឡាកបេង ។
ឆ្លើយគ្នាទីមទុំពួល្ងើយល្ងេង
ព្រួយព្រឺសម្រែងចំបែងបង់ ។

ថាឱយើងអើយមិនគប្បី
ង្សារសត្វពន្ធព័ទ្ធរាល់រូបអង្គ
ដើរដេកក្នុងព្រៃព្រួយព្រោះស-
តម្រង់តម្រូវមិនត្រូវច្បាប់ ។

ប្រសិនខ្លួនខ្ពស់រស់ត្រដូច
មានពាក្យដំនៀលដៀលអឺងអាប់
ប្រសិនបើខូចខុសសណ្ដាប់
ស៊ូស្លាប់ព្រោះស្រីអប្រិយប្រាណ ។

៣២៥. ណាព្រួយលោកត្រូយូរពេលជ្រាប
ថាសិស្សគ្រាន់បើលោករាប់អាន
ថាឯងតូចទាបផៅសន្តាន
អោយពរស្មោះស្មានក្សាន្តព្រះទ័យ ។

ដល់លោកជ្រាបការថាឯងព្រើល
ស្លាប់ខ្លួនអាសារក្នុងពនាល័យ
ងមើលដើរដេកដោយដងព្រៃ
ព្រះគុណនឹងភ័យស្តាយស្រណោះ ។

គ្រានោះគ្រោះជាវេលាយប់
លួមចរចាកចេរលីលាដោះ
ភ្លឺស្វាងមើលគ្រប់ឃើញប្រលោះ
ដើរចេញចាកចុះមកដល់ដី ។

ទុំពេជ្រគេចយល់សកលឋាន
ចរចូលរកសុំបាយចំណី
លួមស្មានដល់ភូមិផ្ទះពីរបី
ស៊ីផ្លែតដូចចិត្តចេតនា ។

ស្រេចហើយចេញចាកលាកលោកទៅ
បក្សីឈ្មោលញីទុំរុក្ខា
កាត់ដើរសំដៅយល់បក្សា
ទុំមានវាចាសាកសួរពេជ្រ ។

៣៣០. ថាអូនមើលសត្វច្រវាត់ទុំ
លលកហើរជ្រកដើមព្រួសព្រេច
មៀងមុំទីទុយហើរលលេច
ពពេចហើរគេចដើមពពូល ។

សេកយំទុំវែងចំបែងគិត
មិនទាន់ដល់ទៅទាវនាងចូល
ដល់ទាវឆោមស្និទ្ធមិនមិត្រមូល
ចិត្តចាំអនុកូលឬទេសោះ ។

ដូចឆ្កួតរូតរឹតខឹងខំដើរ
ទៅដល់ទាវយល់គ្មានស្រណោះ
នឿយព្រួយដំណើរប្រឹងផ្លេះផ្លោះ
ក្រៀមក្រោះអស់មានទេដឹងអើយ ។

ដើរទៅពីទិសនោះឆ្ពោះដល់
ក្រឡុកយល់ក្មេងហៅមិនឆ្លើយ
ដែនដងថ្នាក់ថ្នល់ជិតបង្កើយ
អង្វរវាហើយណាស់នឹងស្ដី ។

វានូវត្លូកនទាំងប៉ុន្មាន
ទុំពេជ្រនិយាយថារ៉ុយរ៉ុ
រូបប្រាណធំក្លិនអាចម៍ក្របី
អាឯងកុំភ័យនឹងអ្វីឡើយ ។



៣៣៥. យើងចង់ជួលអាអោយលុយកាក់
អោយហ៊ានទាំងអស់ប្រុងចាំឆ្លើយ
កុំអោយសល់ម្នាក់ថាអោយហើយ
ក្មេងអើយអញសួរគួរឯងប្រាប់ ។

ក្មេងផងហើយហាថាសួរម្ដេច
ដោយច្បាស់សុខចិត្តតាមសណ្ដាប់
បើចង់ដឹងកិច្ចគួរដោយច្បាប់
គិតខ្លាចដឹងស័ព្ទចាប់សម្ដី ។

ទុំពេជ្រលោលេចមានវាចា
ឯផ្ទះនាងទាវល្អប្រិមប្រិយ
ថាបើអាវ៉ាយើងគប្បី
ឆ្ងាយណាស់ពិសីទើបដើរដល់ ។

ទាវមានប្ដីហើយឬទេនាង
អោយអស់ស្មោះត្រង់តាមយោបល់
ប្រាប់បងកុំវាងពិតតាមស្គាល់
ឬលីវទេទាល់សល់ទទេ ។

ក្មេងផងសាសងប្រាប់វិញជាក់
តែឆ្ងាយប្រមាណព្រះសុរិយេ
ផ្ទះទាវបើស្នាក់នៅមានគេ
ទាបទន់ជ្រៀតជ្រេទើបទៅដល់ ។

៣៤០. គាត់មានតែម្ដាយមេម៉ាយស្អាត
ចិត្តជាអ្នកធម៌ធ្វើមគ្គផល
មានខ្ញុំសង្ខាតខាងកុសល
តម្កល់ចិត្តជឿដើរទៅឆ្ងាយ ។

ទុកទាវជាកូនអោយទំនេរ
នៅនឹងភីលៀងលេងលែបខាយ
ចាំផ្ទះឋិតថេរតែរៀងអាយ
សប្បាយសងស៊ានមិនមានហ្មង ។

អើយើងជម្រាបសភាពពិត
មេត្តាប្រាប់ណាំអោយដឹងផង
ជាញាតិឆ្ងាយជិតឬអ្នកបង
បំណងចង់ជាក់កុំអាក់អន់ ។

ទុំប្រាប់ទៅក្មេងលេងសម្ដី
ល្បីទៅថាទាវចេះថ្នាំស្គន់
ថាអើឯងវ៉ុយើងមកបន់
ថ្នាំស្ងូវគ្រេចក្លួនកមប្រមេះ ។

ទើបអ្នកពីរប្រាណបានឮស័ព្ទ
ខំស្រូតដល់ភូមិទុំពេជ្ររិះ
ក្មេងផងប្រាយប្រាប់ដោយសំណោះ
ថានេះឬម្ដេចពេជ្រផ្ទះទាវ ។

៣៤៥. ពេជ្រឆ្លើយទុំអើយកុំបារម្ភ
គេខឹងប្រកាន់វង្សព្រោះព្រាវ
កុំរួសបង្ខំក្រែងអ្នកក្រៅ
រកផ្ទះដែលនាវនាងទាវទុក ។

ត្បិតកាលយើងមកគាត់រាប់ការ
សមគេសម្គាល់ចំណាំមុខ
ម្ដាយធម៌ម្ដាយអាធិថាទំនុក
ទីសុខយើងសេពអែបរកគ្មេរ ។

និយាយគ្នាស្រេចបាច់ខំដើរ ពើបពានអ្នកថ្មើរទុំរេះរេរ
មិនហ៊ានសើបសួរខ្លាចលោជេរ រិះរេបែរយល់ស្គាល់មិនជាក់ ។
ទើបទុំលើកហត្ថប្រណិបតន៍សួរ ថាគួរមិនគួរសូមទានអ្នក
ផ្ទះហ្នឹងម្ដាយធមិខ្ញុំកុំលាក់ ខ្ញុំធ្លាប់ពឹងពាក់សំណាក់នៅ ។
ទើបអស់អ្នកផងសាសងឆ្លើយ ថាអើមែនហើយចូលតាមផ្លូវ
ធ្លាប្រែករបងកន្លងត្រូវ រួចទៅដល់ផ្ទះច្បាស់មែនហើយ ។
៣៥០. បណ្ឌិតទាំងពីរលីលាដល់ មើលស្គាល់ប្រាកដពុំលង់ឡើយ
ហាហៅម្ដាយធមិអរឆ្លាស់ឆ្លើយ កូនអើយបាត់យូរក្រមកដល់ ។
ទុំពេជ្រអរស្រេចគេចឡើងផ្ទះ លើកដៃសំពះឱនកាយកល់
នាងជាម្ដាយធមិនៅជិតផ្ទាល់ សួរសុខទុក្ខផ្ទាល់មិនសល់សព្វ ។
សួរសាកម៉ែឪនៅភូមិស្រុក ថាម៉ែមើលមុខមិនហ៊ានស្អប់
ទើបនាងម្ដាយធមិថាដូចផប់ កូនដើមមកផ្ចប់ផ្ទៀងនៅអាយ ។
ទុំឆ្លើយថាខ្ញុំសូមប្រណិប័តន៍ ទាន់ស្វាត់ជម្រាបរៀបរាប់រាយ
ខ្លួនខ្ញុំសូមសុំអោយលោកម្ដាយ ចិត្តពុំនឿយណាយចាយសម្ដី ។
ភរភូតកុហកឡកលាក់បាំង មកនេះខ្ញុំអាងត្បិតទាវស្រី
ប្ដេជ្ញាបណ្ដាមានសាក្សី ទន្ទាប់ចារីស្លាផាហ៊ុម ។
៣៥៥. យើងនឹងឈប់ស្ទេះបង្អង់នៅ រឿងពេជ្រទុំទៅដល់ត្បូងឃ្មុំ
នឹងថ្លែងដំណើរអរជូនជំ- នុំនឹងភរិយាជាប្រពន្ធ ។
ថានៃប្អូនស្ងួននួនខ្លីមចិត្ត យើងគួរបីត្បិតបងមានបុណ្យ[១]
មានបុត្រស្រីប្រុសរបស់ធន បណ្ដាមហាជនជុំក្រាស់ក្រន ។
បងព្ធអស់រាស្ត្រប្រជាជាក់ និយាយមិនលាក់ដូចមាំមួន
ប្រាយប្រាប់ដោយសព្វសក្ដិសមសួន កូនគេផងខ្លួនដូចងូនយើង ។
នាងនោះមានម្ដាយមេម៉ាយសោះ ប៉ុន្តែរបស់តាមទំនើង

១. ច្បាប់ខ្លះថាត្បិតយើងសព្វថ្ងៃនេះយើងមានបុណ្យ ។



មែនបានបាវព្រាវប្រើលាងជើង ថ្មុំថ្មើងគ្រប់សព្វចប់ដល់ចាស់ ។
ប្រពន្ធបានស្ដាប់ចាប់ចិត្តចំ ជឿជាសួនសមមិនទាន់ច្បាស់
ជម្រាបទៅប្ដីថាអម្ចាស់ ខ្ញុំស្ដាប់ប្រសាសន៍លះគុំគួន ។
៣៦០. ថាគិតផ្គងផ្គុំផ្សំកូនគេ ស្រែឬទន្លេដែលមានខ្លួន
ចិន្ដាលោភគិតអោយម៉ឺនងួន ចំណាយចំនួនឆ្នាំខែថ្ងៃ ។
អរជូនជញ្ជីងរង់ចាំស្ដាប់ ប្រពន្ធសាស័ព្ទនៅសង្ស័យ
ទើបគាត់ប្រាប់ថាប្អូនមាសថ្លៃ បងឮសម័យដោយប្រជា- ។
នុរាស្ត្រនុរៈអ្នកប៉ុន្មាន ដែលបានមកដល់ជំនុំគ្នា
សរសើរពីរូបទាវសោភា នៅនាខាងក្បែរស្រែទេស្រី ។
នេះបើប្អូនស្ងួននួនខ្លីមចិត្ត យើងគួរអាណិតបុត្រភ្ញាប្រិយ
គួរយើងរិះរកនំចំណី ភោជ្យផលអ្វីៗត្រីសាច់សត្វ ។
រួចរើសរកអ្នកជាក់ចេះដឹង មែនមានដំណឹងរឿងបរមត្ថ
ដែលតែងប្រសប់ធ្លាប់តែកាត់ សំស្នាត់បែបបទចេះវោហារ ។
៣៦៥. អធិប្បាយនិយាយខាងចែចូវ ជាអ្នកនាំផ្លូវតាមដូនតា
អោយទៅស្រដីខាងមេបា នាងទាវថាតើប្រការម្ដេច ។
ប្រពន្ធអរជូនជំនួនស្រាប់ ភ្ជុំគ្នាប្រញាប់រ៉ាន់រំពេច
យកសព្វភោជ្យផលថ្កល់នឹងវេច រៀបរួចស្រាប់ស្រេចត្រាច់ចរចេញ ។
លីលាលលង់ដានដងផ្លូវ ត្រូវត្រង់មាគ៌ាឃ្នាតខ្នលខ្ទាញ់
ខំស្រូតរូតរះកាត់គ្រោកគ្រាញ់ អរញ្ញវាព្រៃរំពៃយល់ ។
ក្រឡេកក្រលៀងឆ្មៀងពីអាយ ច្បាស់ជានាងម្ដាយទាវនិមល
នេះតីមិនអ្នកដទៃទាល់ ទៅជិតទៀបស្គាល់ដល់ជាម្ដង ។
នាងនោះស្ទុះឡើងលើគ្រឹះស្ថាន ប្រមាណត្រូវមាត់ជាជន្លង
ថាអ្នកអញ្ជើញមកប៉ុនប៉ង បំណងបំណាច់ត្រាច់ទៅឆ្ងាយ ។
៣៧០. ឬមួយជាមករកយើងខ្ញុំ សូមសុំប្រសាសន៍សងរ៉ាប់រ៉ាយ

អោយដឹងកិច្ចកលអធិប្បាយ
អ្នកទាំងប៉ុន្មានបានដល់ផ្ទះ
នំដាក់តុស្ពាន់វន្ទាន់យក
ថាយើងខ្ញុំមកដោយចិត្តស្ម័គ្រ
ទោះបីមោះហ្មងសូមលន់តួ
ត្បិតលោកចៅហ្វាយនូវអ្នកស្រី
ចាត់ប្រើយើងខ្ញុំនាំបណ្ដា-
ប្រៀបដូចថ្នល់ស្ពានឈានរត់ដើរ[១]
ដណ្ដឹងកូនអ្នកត្បិតឮល្បី
៣៧៥. នាងជាមេម៉ាយម្ដាយទាវស្ដាប់
ទទួលថាអើសរសើរខ្លួន
វិស័យសព្វថ្ងៃលំបាកដែរ
ប៉ុន្ដែខ្ញុំថាកូនធុរៈ
មិនដឹងទាន់ព្រមល្មមមេត្រី
ព្រោះតែយើងរាស្ត្រគួររាំងរា
ឧកញ៉ាអរជូនមូនមាំពេក
មានឫទ្ធិអំណាចឥតជំនុំ
គួរហើយខ្ញុំសូមជំរាបញាតិ
ថាបើលោកចង់ចងមេត្រី
៣៨០. នាងអ្នកស្ដាប់ជាក់ចាំរាល់គ្នា
ប្រគល់ម្ដាយទាវស្រេចអង្គឱន
ចរចុះវិលទៅលំនៅស្ថាន
ឡើងប្ដឹងអរជូនជុំភិរិយា
ថែងចាយកំលាក់អោយឡើងមក ។
ម្ដាយទាវអរណាស់ទើបរៀបស្លក
ឡើងមកលើផ្ទះសំពះសួរ ។
ទទួលធុរៈគួរមិនគួរ
ឆ្អែងជូរដូចម្ដេចសូមមេត្តា ។
ទាំងពីរទាំងបីមានវាចា
ការមកប្រាថ្នាចងមេត្រី ។
សុំស្នើសុំស្នាក់អ្នកថាអ្វី
កូនស្រីស្ដីផ្សំចំម៉ឺនងួន ។
ចំណាប់ចំណងត្រូវចិត្តជូន
អ្នកអើយច្បាប់ក្បួនកូនកបលក្ខណ៍ ។
គេមកហួរហែដូចឥតអាក់
ញាតិផងប៉ងស្ម័គ្រមកច្រើនគ្នា ។
អោយទៅមន្ត្រីរាស្ត្រប្រជា
ឥឡូវទើបពារលើលោកធំ ។
ធម្មតាក្រោមមេឃទាបជាងភ្នំ
កាប់ចាក់វាយដំពុំប្រណី ។
ទៅសំពះបាទលោកប្រុសស្រី
គប្បីចាំខ្ញុំលបសួរកូន ។
រួចលើកភស្តុភារជាជំនូន
លំទោនលើកហត្ថប្រណិបតន៍លា ។
ទាំងអស់ប៉ុន្មានចរលីលា
ចាំជាបែបបទប្រាកដណាស់ ។

១. ច្បាប់ខ្លះថា ឈានដោយស្ម័គ្រ



វេលាក្រោយនោះចំពោះជា
ឃើញនំភស្តុផលថ្កល់តុថាស
ហើយសួរទៅកូនថាមាសម្ដាយ
ម្ដាយអោយទៅកូនចៅហ្វាយស្រុក
អំណាចខ្លបខ្លាចមានស័ក្តិយស
ម្ដាយប្រាប់ប្រដៅកូនកុំឆ្អើង
៣៨៥. ទាវឮម្ដាបប្រាប់ចាប់ចាំទុក
ទើបមានវាចាថាម៉ែអាយ
ថាបើម៉ែព្រមល្មមនឹងគេ
លើកអោយគេទៅទោះពីរបី
ទទួលទទូចខូចការហើយ
ម៉ែមានកូនគួររៀបផ្សំផ្គុំ
នាងម្ដាយចាំស្ដាប់ស័ព្ទទាវឆ្លើយ
បន្ទន់អន់អត់មើលមុខក្រោយ
គិតក្រែងបែកបាក់ធ្លាក់ថ្លោះធ្លោយ
ប្រមៀលត្រូវថ្មល្អិតគ្មានសល់
៣៩០. នៃទាវទំនៀមព្រាងប្រៀបស្រាប់
លោកយកទាញមករកសន្ធឹង
មិនដែលសោះឡើយទាវអើយនំ
កូនគោកាចក្បៀចដោយព្រៃវាល
ស្លេះឈប់សម្ដែងថែងដំណាល
និយាយពីទុំនៅជុំស្រាប់
មួយប្រៀបឧបមាចិន្ដាទុំ
ថាប្អូនពេជ្រអើយយើងមកបាន
ម្ដាយទាវម្ដីម្នាដូចអរណាស់
រហ័សរៀបចំសន្សំទុក ។
សមយើងសប្បាយថ្លាវិកមុខ
បានសុខដោយបុណ្យដោយបានថ្កើង ។
ចំពោះជាត្រូវបុណ្យកូនឡើង
ចចេសចចើងណាំថ្លៃម្ដាយ ។
ស្មើរធ្លាក់ថ្លើមក្ដុកកុំរសាយ
ខ្ញុំកូនដូចស្ដាយបាយចំណី ។
កូនម៉ែទំនេរមានប្រុសស្រី
តាមម៉ែមេត្រីអោយថ្វីខ្ញុំ ។
ខុសសោះហ៊ានឆ្លើយថាម៉ែកុំ
ឃើញលោកបុណ្យធំលើកខ្ញុំអោយ ។
ប្រាប់ថាទាវអើយគួរបណ្ដោយ
ធ្វើខ្សោយសិនចុះកុំផ្ចញ់ផ្ចាល់ ។
ពងមាន់មកអោយមានអំពល់
ហ៊ានទល់ផ្ទាល់ផ្ចញ់សង្កញខឹង ។
ថាកូនមិនស្ដាប់ចចេសរឹង
របឹងរបាញសាញចណ្ដាល ។
ច្រឡើសបើសធំម្ដេចជាងនាឡិ
រោលរាលឈឺខ្លួនជូនដល់ស្លាប់ ។
ម្ដាយទាវរាលដាលជាលំដាប់
ដឹងសាប់ចាប់ព្រួយតែមួយប្រាណ ។
ជំនុំនឹងពេជ្រស្រេចស្មោះស្មាន
សម្រាន្ដយូរថ្ងៃវិស័យបង ។

ស្ទើរបែកប្រមាត់ខ្ទាត់ពីរបី　　ទុក្ខបងបែកស្រីទាវយូរផង
មិនទាន់បានជួបនឹងនួនល្អង　　នេះម្តងសមឃ្លាតយូរថ្ងៃហើយ ។
៣៩៥. ពេជ្រអោយបងទៅឬអោយឈប់　　ខានប៉ុន្មានយប់ទៀតពេជ្រអើយ
កុំនៅបង្អង់អោយលង់ឡើយ　　ចូរឆ្លើយចូរឆ្លៀតសង្កេតគិត ។
ប្រសិនជាបងមិនបានទាវ　　ដែលនាវដល់នឹងក្ស័យជីវិត
បើបងឃើញប្រាណស្មានក្នុងចិត្ត　　នោះឥតកុំដឹងនឹងនៅអាយ ។
ផ្ញើអស់អង្គប្រាណលើមាសថ្លៃ　　វិស័យខ្លួនបងដូចទន្សាយ
បានជ្រកគុម្ពោតកំពស់ឆ្ងាយ　　ឱនកាយខ្វាយទុក្ខសុខតទៅ ។
ពេជ្របានស្តាប់ទុំជំនុំផង　　ឆ្លើយថាចូរបងទុំខ្ញុំទៅ
អ្នកឯងប្រយ័ត្នក្រែងដោយផ្លូវ　　សត្រូវធ្វើកលផ្តល់ផ្តាច់ជន្ម ។
កុំទុកចិត្តស្រីស្តីមាយា　　មារយាទមួយវាចិត្តមិនធូន់
ថាយើងចង់បានធ្វើប្រពន្ធ　　ទំរន់រកទ្រព្យងាប់អសារ ។
៤០០. ទុំបានស្តាប់ពាក្យពេជ្រប្រដៅ　　ថាអើនេះហៅមានប្រាជ្ញា
តែប្អូនកុំភ័យស្រីណាៗ　　ទើបវាប្រាថ្នាចង់អោយស្លាប់ ។
នាងទាវល្អល្អងបងស្រឡាញ់　　ចិត្តមូលលើអញទើបហ៊ានភ្ជាប់
របស់បញ្ជាំផ្តាំផ្តួផ្តាប់　　យើងរាប់រឿងចិត្តត្បិតទាវស្ម័គ្រ ។
លង់លុះពេជ្រទុំជំនុំស្រេច　　ទុំលាពេជ្រត្រាច់ចង់ជួបជាក់
ថាឱប្អូនស្ងួននួនវរលក្ខណ៍　　នួនអ្នកភ្លេចហើយឬចាំនៅ ។
គិតហើយចេញដើរតែម្នាក់ឯង　　កើតទុក្ខកណ្តែងកណ្តាលផ្លូវ
លន្លង់លន្លោចខ្លោចផ្សាក្តៅ　　ដើរជិតទៀបទៅផ្ទះទាវស្រី ។
គ្រានោះម្តាយទាវគាត់មិននៅ　　ចរចេញដើរទៅមុខឆ្ងាយក្រៃ
ទុំដើរទៅឈប់ឈរសង្ស័យ　　ទាវឃើញថាហៃបងនោស្រី ។
៤០៥. បងទៅសួរគាត់អោយបានជាក់　　ក្រែងមានធុរៈមករកអ្វី
នោពួទាវប្រាប់ទៅឆាប់ខ្មី　　អ្នកអើយរកអ្វីអញ្ជើញមក ។





ទុំស្តាប់សាស័ព្ទនៅសម្ងំ ឮនោហៅចំទើបទុំក្រោក
ឈានឡើងលើផ្ទះហើយនោភ្ញក សួរថាអ្នកមករកការអ្វី ។
ទុំស្តាប់សាស័ព្ទពាក្យនោសួរ ទុំប្រាប់ដោយគួរជាមេត្រី
បងមករកទាវទេណាស្រី ត្បិតនាងទាវស្រីស្ព័សញ្ញា ។
នោឆ្លើយអ្នកអើយគួរពិភាល់ ប្អូនខ្វល់ឆ្ងល់ឆ្ងាយក្នុងចិន្តា
ទុំថាឆ្ងល់អ្វីកុំសង្កា បានមើលសាស្ត្រាស្លុត្រអោយស្តាប់ ។
ឥឡូវធ្វើឆ្វើងថាមិនស្គាល់ មានជាបន្ទាល់នៅដៃស្រាប់
ប្រាថ្នាមានឈ្នួតនិងដន្លាប់ អោយបងសឹកឆាប់កុំយូរឡើយ ។
៤១០. ទាវឮពាក្យទុំថាដូច្នោះ ព្រឺព្រួចពុងពោះពុំមានស្បើយ
បើកទ្វារចេញមកថាលោកអើយ ហ៊ានយកឈ្នួតហើយជាបន្ទាល់ ។
នរណាផ្តាំថានឹងឈ្នួតទៅ អោយអ្នកមកកួវនាំកង្វល់
ទុំថាបើបានតែដៃដល់ ប្រាប់មិនអោយឆ្ងល់សល់សេចក្តី ។
ទាវថានរណាបានប្តេជ្ញា កោតតែវាចាហ៊ានស្រដី
ចូលអ្នកវិលទៅលំនៅខ្ចី កុំនៅធ្វើអ្វីឃើញពុំជា ។
ទុំថានរណាគេនឹងឆោត វិលទៅវិញសោតអោយឃ្លាតឃ្លា
នៅទាល់តែបានកែវពុំងារ មូលមួយផងគ្នាមិនបែកបង់ ។
ខ្លួនប្អូនសព្វថ្ងៃប្រៀបដូចផ្កា ឯអ្នកឧបមាដូចកន្លង់
ហើរកឃើញផ្កាចូលត្រើបត្រង់ រួចមិនបង្អង់ត្រាច់លីលា ។
៤១៥. ទុំថាខ្លួនបងដូចរាជសីហ៍ ខ្លួននាងទាវស្រីដូចគុហា
រាជសីហ៍បើបានលំនៅជា មិនអោយឃ្លាតឃ្លាគុហាឡើយ ។
ទាវថាខ្លួនប្អូនដូចកំពង់ ខ្លួនអ្នកឆោមយង់ដូចទូកហើយ
ចាប់ចតអាស្រ័យអ្នកថ្លៃអើយ ចេញទៅកន្តើយមិននឹកនា ។
ទុំថាឱបងដូចត្រីធំ ខ្លួនទាវក្រមុំដូចគង្គា
ត្រីបានទឹកជ្រៅហែលរេរា កុំកែវពុំងារគិតសង្ស័យ ។



ទាវថាខ្លួនប្អូនដូចព្រឹក្សា អ្នកដូចសារិកាទំសព្វថ្ងៃ
ចតជាទ្រនំទំអាស្រ័យ ហើយហើរច្រៀងច្រៃទៅទីទៃ ។
ទុំថាខ្លួនបងប្រៀបដូចខ្លា ខ្លួនកែវកន្និដ្ឋាប្រៀបដូចព្រៃ
ធម្មតាសត្វខ្លាមិនវិលវៃ ចៀសចេញចោលព្រៃណាំថ្លៃបង ។
៤២០. ខ្លួនប្អូនដូចឈើជាបង្គង ខ្លួនអ្នកប្រុសឈ្លងដូចឃ្មុំផង
មកទំផ្ញើសាំហើរជាម្តង ឈើសោតសៅហ្មងអសារនៅ ។
ទុំថាខ្លួនបងដូចដរី ខ្លួនប្អូនស្រស់ស្រីដូចអំពៅ
ដរីបានផ្អែមមិនដែលទៅ ឆ្ងាយពីអំពៅណាំអូនណាំ ។
ទាវថាឱះឱអ្នកថ្លៃអើយ នរណាដោយហើយកុំសង្កា
ពាក្យប្រុសភូតព្រាងអាងប្រាជ្ញា កុំណាំខ្ញុំថាកុំសង្ស័យ ។
ទាវមានវោហារប្រាជ្ញាដោះ ទុំគ្មានខ្លាចសោះចូលចាប់ដៃ
ថើបថៃថានែអ្នកមាសថ្លៃ នៅតែសង្ស័យមិនជឿចិត្ត ។
ទាវខឹងក្រញឹងឥតកោតក្រែង ចាប់ដៃកំហែងគ្មានអាណិត
ទឹកទៅគួរខ្លាញ់ម្ទេញមិនស្និត កោតចិត្តហៅហ៊ានរុករានព្រៃ ។
៤២៥. ហ៊ានមកថើបថ្ពាល់ពាល់ដល់ដោះ ចិត្តគ្មានក្រែងសោះមិនខបថៃ
ទុំថាបើខុសសូមអោយថ្លៃ ស្រឡាញ់យូរថ្ងៃឥតឧបមា ។
នាងនោភីល្បៀងដឹងសេចក្តី ចរចុះចេញខ្ចីមិនមានថា
ក្រែងទាវអន់អៀនក្នុងកាយា ចិន្តាទាវព្រមល្មមបេតី ។
ទុំឱបបីបមផ្ទមប្រឡែង ទាំងពីរឥតក្រែងរួមមេត្រី
នៅក្នុងគ្រឹះស្ថានក្សាន្តដូចក្តី ស្រស់ស្រីស្រួលស្រើបដោយតណ្ហា ។
ទាវស្រួលទទួលព្រមចូលជិត ទុំសោតស្នេហ៍ស្និទ្ធថើបភ័ក្ត្រា
ទាំងពីរហ៊ានស្បថប្រាកដថា ខ្នាក់ស្វាប្តូរគ្នារួចទាវឆ្លើយ ។
អ្នកថ្លៃប្អូនអើយក្រែងអ្នកបង បានរួមស្នេហ៍ស្នងនៅក្បែកកើយ
ចេញចាកចោលប្អូនទេដឹងអើយ អ្នកអើយអាសូរចិត្តប្អូនរ៉ា ។

៤៣០. ទុំថើបល្អងលោមថ្ពៃនួនល្អង    ថាឱមាសបងដួងជីវា
បងមិនដោះដៃចោលកនិដ្ឋា    បងផ្ញើអត្តាអស់ជន្មជីព ។
ត្បិតប្អូនមានគុណប្រៀបដូចភ្នំ    សុមេរុធារធំសង្កត់ទ្វីប
ខ្លួនបងធៀបដូចកលស្លូត្រីព    ជន្មជីពផ្ញើលើព្រះរាមា ។
ទាវថាខ្លួនប្អូនដូចតារា    ប្រុសថ្លៃស្នេហាដូចចន្ទ្រា
តារារះរាយលើមេឃា    អមអង្គចន្ទ្រាមិនមានឃ្លាត ។
បងអើយយប់ហើយចូលសយនា    ស្និទ្ធស្នាលស្នេហាលុះអាធ្រាត្រ
ទុំសុំប្រាថ្នាជួបសព្វជាតិ    ពុំឃ្លាតពុំឃ្លៀងរៀងតទៅ ។
ថ្លាថ្លែងពីនាងម្ដាយទាវវិញ    មកពីបុណ្យ [1]វិញដល់លំនៅ
ទាវសោតបានដឹងដំណឹងកូវ    អោយទុំចេញក្រៅរួសជាម្ដង ។
៤៣៥. ពាក្យពេចន៍បានមត់នឹងនោគ្រប់    ទាវនៅក្នុងម្លប់ឥតមានហ្មង
ម្ដាយទាវមកដល់ផ្ទះដូចប៉ង    ខ្ញុំប្រុសស្រីផងចូលមកដល់ ។
ម្ដាយទាវឃើញទុំទៅសួរថា    អ្នកមកពីណាគួរពិភាល់
ទុំថាខ្ញុំមកពីឆ្ងាយសល់    ទើបដល់វេលានាថ្ងៃមិញ ។
ម្ដាយទាវសួរទុំចង់ដឹងដាន    ថានៅប៉ុន្មានថ្ងៃវិលវិញ
ទុំថាខ្ញុំមកដើររកទិញ    ទំនិញគោសេះស្លេះរំខាន ។
ត្បិតមកពីឆ្ងាយគ្នាពីរនាក់    អោយនៅសំណាក់ក្នុងគ្រឹះស្ថាន
ផ្ទះគេចំណាំធ្លាប់រាប់អាន    ពីដើមខ្ញុំបានស្ដូត្រអោយស្ដាប់ ។
ម្ដាយទាវដឹកជាក់ហាក់ដូចស្រួល    ទទួលអោយនៅហើយប្រាយប្រាប់
អ្នកកូននៅចុះទោះយូរឆាប់    ទំនួលទុំស្រាប់អរឥតក្រែង ។
៤៤០. ម្ដាយទាវសោតរៀបកន្ទេលខ្នើយ    បម្រុងអោយហើយរួចចារចែង
អ្នកកូនដេកនៅទីកន្លែង    យើងតែងរៀបទុកអោយអ្នកថ្លៃ ។
កាលនោះឯទុំឆោមពិសី    នៅនឹងទាវស្រីរូមភិសម័យ

១. ច្បាប់ខ្លះថា មកពីក្រៅ



តាមដោយចិត្តគាប់បទអាល័យ    យូរថ្ងៃមិនអោយគេដឹងដាន ។
ទុំភ្លេចភូមិស្រុកមិននឹកនា    ពេជ្រប្អូនពុំងារជាពីរប្រាណ
ឥតមានទុច្ចរិតរីតរំខាន    សុខទុក្ខស្នេហ៍គ្រស្មានតែពីរនាក់ ។
គ្រាក្រោយថ្លាថ្លែងពីម៉ឺនងួន    កូនលោកអរជូនមានមាសប្រាក់
យកមកផ្គាប់ផ្គន់ទាវវលក្ខណ៍    ប្រមាណ [1] ទាវស្ម័គ្រស្មោះនឹងខ្លួន ។
មិនដឹងកលកិច្ចគេឧបាយ    ទាវមានសាហាយទេម៉ឺនងួន
សរសើគេថាហៃប្អូនស្ងួន    នាងនួនល្អដាច់ស្រេចផែនដី ។
៤៤៥. ប្រសិនស្ងួនព្រមល្មមចិន្ដា    បងថ្នមកន្និដ្ឋារូមមេត្រី
មិនអោយមានមួយជាពីរបី    បងថ្នមប្អូនស្រីកែវចរណៃ ។
ម៉ឺនងួនទៅមកមិនហ៊ានខាន    ម្ដាយទាវរាប់អានស្រឡាញ់ក្រៃ
នាងទាវមិនស្និតឥតសង្ស័យ    ទាវថប់វិស័យពុំស្រដី ។
រីឯដំណើរអំបាលនោះ    នឹងបញ្ឈប់ស្លេះទុកសិនខ្ចី
ថ្លាថ្លែងពីអង្គព្រះចក្រី    ស្ដេចគង់បូរីរដ្ឋរាជស្ថាន ។
ស្ដេចគង់នគរកម្ពុជា    ឈ្មោះព្រះរាមារិទ្ធិថ្កើងថ្កាង
អស់រាស្ត្រប្រជាសឹងសុខសាន្ត    រាជស្ថានស្ដេចគង់បន្ទាយលង្វែក ។
មានវាំងដំណាក់ទីប្រាសាទ    ប្រសើរស្អាងស្អាតខ្ពស់អនេក
រោងរ័ត្ន [2] រោងរាំរបាំឯក    ល្អប្លែកបីដូចស្ថានសួគ៌ា ។
៤៥០. ស្ដេចមានព្រះអគ្គមហេសី    រូបឆោមប្រិមប្រិយល្អសោភា
គ្រប់លក្ខណ៍ល្មាសល្ងទ់ឥតគណនា    មិនមានរោគាព្យាធិអ្វី ។
ជុំញាតិវង្សាពង្សាវតារ [3]    អស់ទាំងសេនាមុខមន្ត្រី
ជាទីសម្រាប់បុណ្យបារមី    គាល់អង្គចក្រីស្ដេចរាមា ។
មានរោងរាជយានអស្សតរ    រាជរថបវរគជេន្ទ្រា
មានទីគ្រឿងល្បែងឥតគណនា    សឹងនាំទ្រព្យាជាដង្វាយ ។

១. ច្បាប់ខ្លះថាស្មានថា ។   ២. ច្បាប់ខ្លះថារោងរដ្ឋ ។   ៣. ច្បាប់ខ្លះថាជួបជុំព្រះញាតិវង្សា ។